ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# មេរៀនសង្ខេប

# មុខវិជ្ជា៖ រូបវិទ្យា

សម្រាប់ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
និងបំពេញវិជ្ជាលើកទី២

សម័យប្រឡង ១៣ តុលា ២០១៤

## ជំពូក១ ទែម៉ូឌីណាមិច

## មេរៀនទី១៖ ទ្រឹស្តីស៊ីនេទិចនៃឧស្ម័ន

ទំនាក់ទំនងសីតុណ្ហភាពដាច់ខាតនិងសីតុណ្ហភាពគិតជាសែលស្យុស

$$T = T_C + 273.15$$

$T$ ជាសីតុណ្ហភាពដាច់ខាតគិតជា$(K)$, $T_c$ ជាសីតុណ្ហភាពសែលស្យុស°C

ក្នុងទ្រឹស្តីស៊ីនេទិចនៃឧស្ម័ន៖ ម៉ូលេគុលឧស្ម័នមានចលនាឥតឈប់ឈរ និងគ្មានសណ្តាប់ធ្នាប់។ ទង្គិចរវាងម៉ូលេគុលនឹងធុងផ្ទុកវាជាទង្គិចខ្ទាត។ សន្មតនៅចន្លោះពេលទង្គិចម៉ូលេគុលមានចលនាត្រង់ស្មើ។ តម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលអាស្រ័យនឹងសីតុណ្ហភាព។

សម្ពាធនៃឧស្ម័នសមាមាត្រនឹងចំនួនម៉ូលេគុលក្នុងមួយខ្នាតមាឌនិង តម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុល $P = \frac{2}{3}\left(\frac{N}{V}\right)K_{av} = \frac{2}{3}\left(\frac{N}{V}\right)\frac{1}{2}m(v^2)_{av}$

$P$ ជាសម្ពាធឧស្ម័នគិតជា$(Pa)$, $N$ ជាចំនួនម៉ូលេគុលឧស្ម័ន, $V$ជាមាឌធុង$(m^3)$
$m$ ជាម៉ាសរបស់ម៉ូលេគុលឧស្ម័ននីមួយៗ$(kg)$, $v$ ជាល្បឿនរបស់ម៉ូលេគុលឧស្ម័ន$(m/s)$

ឧស្ម័នបរិសុទ្ធ$n$ ម៉ូលមានសម្ពាធ$P$ មាឌ $V$និងសីតុណ្ហភាព$T$នោះសមីការភាពនៃឧស្ម័នបរិសុទ្ធគឺ $PV = Nk_BT = nRT$

$P$ ជាសម្ពាធឧស្ម័នគិតជា$(Pa)$, $V$ ជាមាឌឧស្ម័ន $(m^3)$, $T$ សីតុណ្ហភាពឧស្ម័ន$(K)$

$k_B$ជាថេរបុលស្មាន់ $k_B = 1.38 \times 10^{-23} J/K$, $n$ជាចំនួនម៉ូលឧស្ម័ន$(mol)$

$R$ ជាថេរសកលនៃឧស្ម័ន$R = 8.31 J/(mol.K)$, $N$ ជាចំនួនម៉ូលេគុលឧស្ម័ន

ទំនាក់ទំនងរវាងចំនួនម៉ូលឧស្ម័ន $n$ និងចំនួនម៉ូលេគុលឧស្ម័ន $N$ គឺ $n = \frac{N}{N_A}$

$N_A$ ជាចំនួនអាវូកាដ្រូ $N_A = 6.022 \times 10^{23}$ម៉ូលេគុល$/mol$

ទំនាក់ទំនងរវាងថេរបុលស្មាន់ $k_B$ និង ថេរសកលនៃឧស្ម័ន$R$ គឺ $R = k_BN_A$

ថាមពលស៊ីនេទិចមធ្យម នៃម៉ូលេគុលនីមួយៗគឺ $K_{av} = \left(\frac{1}{2}mv^2\right)_{av} = \frac{3}{2}k_BT$

$K_{av}$ ជាថាមពលស៊ីនេទិចមធ្យម នៃម៉ូលេគុលនីមួយៗគិតជាស៊្សូល$(J)$

$T$ សីតុណ្ហភាពឧស្ម័ន$(K)$


facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ថាមពលស៊ីនេទិចសរុបកម្ម៉ូល នៃឧស្ម័ន គឺ $K = \frac{3}{2}Nk_BT = \frac{3}{2}nRT$

$K$ ជាថាមពលស៊ីនេទិចសរុបគិតជាស៊្សូល( J)

ល្បឿនប្រសិទ្ធឬល្បឿនឬសមធ្យមការេ របស់ម៉ូលេគុលឧស្ម័ន

$$v_{rms} = \sqrt{(v^2)_{av}} = \sqrt{\frac{3k_BT}{m}} = \sqrt{\frac{3RT}{M}}$$

$v_{rms}$ ជាល្បឿនប្រសិទ្ធរបស់ម៉ូលេគុលឧស្ម័ន $(m/s)$

$m$ ជាម៉ាសម៉ូលេគុលឧស្ម័ន $(kg)$

M ជាម៉ាសម៉ូល$(kg/mol)$

ទំនាក់ទំនងរវាង ម៉ាសម៉ូលេគុលឧស្ម័ន $m$និងម៉ាសម៉ូលM គឺ $M = mN_A$

ទំនាក់ទំនងរវាង សម្ពាធ គិតជាបាស្កាល់ $(Pa)$ និងសម្ពាធ គិតជាអាត់ម៉ូស្វ៊ែ $(atm)$ គឺ $1\ atm = 1.013 \times 10^5 Pa$ តែដើម្បីមានភាពងាយស្រួលក្នុងការគណនា ក្នុងឧទាហរណ៍ខាងក្រោម យើងយក $1\ atm = 10^5 Pa$ ។

**ឧទាហរណ៍១៖** ឧស្ម័ននីត្រូសែនផ្សំឡើងពីម៉ូលេគុល$N_2$។គណនាម៉ាសម៉ូលេគុល នីត្រូសែន។ ម៉ាសម៉ូលនីត្រូសែនគឺ$M = 28kg/kmol$។

**ចម្លើយ១៖** គណនាម៉ាសម៉ូលេគុលនីត្រូសែន

តាមរូបមន្ត$M = m \times N_A \Rightarrow m = \frac{M}{N_A}$

ដោយ $M = 28\,kg/kmol = 28 \times 10^{-3}\,kg/mol$

$N_A = 6.02 \times 10^{23}$ ម៉ូលេគុល$/mol$

$$m = \frac{28\times10^{-3}}{6.02\times10^{23}} = 4.7 \times 10^{-26} kg$$

**ឧទាហរណ៍២៖** គណនាមាឌដែលផ្ទុកដោយឧស្ម័នអុកស៊ីសែន3.2g នៅសម្ពាធ76cmHg និងសីតុណ្ហភាព 27°c ។

**ចម្លើយ២៖** គណនាមាឌដែលផ្ទុកឧស្ម័ន$O_2$

តាមសមីការភាពនៃឧស្ម័នបរិសុទ្ធ

$$PV = nRT$$

តែn $= \frac{m_0}{M} \Rightarrow PV = \frac{m_0}{M}$ RTតាង$m_0$ជាម៉ាសសរុបរបស់ឧស្ម័ន

គេបានV= $\frac{m_0 RT}{MP}$

ដោយM = 32g/mol; $m_0$=3.2g ; R=8.31J/mol.K; T= 27°C =300K;P= 76 cmHg =1atm=$10^5$Pa

$$\Rightarrow V = \frac{3.2\ \times (8.31)300}{32\times 10^5} = 0.0025m^3$$

ដូចនេះ$V = 0.0025m^3$

ឧទាហរណ៍៣៖ រកល្បឿនប្រសិទ្ធ($Vrms$)នៃម៉ូលេគុលអាសូតដោយម៉ាសម៉ូល M=28g/molនៅ 300K។

ចម្លើយ៣៖ គណនាល្បឿន$V_{rms}$

តាមរូបមន្ត$V_{rms}=\sqrt{\frac{3RT}{M}}$ដោយR=8.31J/molK;

T=300K; M=28g/mol=$28\times10^{-3}$kg/mol

$$\Rightarrow V_{rms}=\sqrt{\frac{3\times8.31\times300}{28\times10^{-3}}}=561.8\text{m/s}$$

ដូចនេះ$V_{rms}=561.8\text{m/s}$

ឧទាហរណ៍៤៖ គណនាសីតុណ្ហភាពដែលធ្វើឱ្យល្បឿនប្រសិទ្ធនៃម៉ូលេគុលអ៊ីដ្រូសែនស្មើ331m/s? គេឱ្យ $M_{H_2}$= 2g/mol។

ចម្លើយ៤៖ គណនាសីតុណ្ហភាពដើម្បីបានល្បឿនប្រសិទ្ធ($V_{rms}$)

$$\mathrm{V_{rms}}=\sqrt{\frac{3RT}{M}}\Leftrightarrow \mathrm{V_{rms}^2}=\frac{3RT}{M}\Rightarrow T=\frac{M.V_{rms}^2}{3R}$$

ដោយ$M_{H_2}$=2g/mol=$2\times10^{-3}$kg/mol; $V_{rms}$ =331m/s និងR=8.31J/mol.K

T=$\frac{2\times10^3\times(331)^2}{3\times8.31}=8.79$K

ដូចនេះ:T=8.79K

ឧទាហរណ៍៥៖ គណនាថាមពលស៊ីនេទិចមធ្យមក្នុងមួយម៉ូលេគុលនៃឧស្ម័ននៅសីតុណ្ហភាព 727℃ គេឱ្យ R=8.32J/mol.K និង$N_A=6.022\times10^{23}$ម៉ូលេគុល/mol។

ចម្លើយ៥៖ គណនាថាមពលមធ្យមនៃម៉ូលេគុលឧស្ម័ននីមួយៗ

តាម $K_{av}=\frac{3}{2}k_BT$ដោយ$R=k_BN_A\Rightarrow k_B=\frac{R}{N_A}$

$K_{av}=\frac{3}{2}\frac{RT}{N_A}$តែT=727°C=1000K

នោះគេបាន $K_{av}=\frac{3}{2}\times\frac{8.31\times1000}{6.022\times10^{23}}=2.07\times10^{-20}J$

ឧទាហរណ៍៦៖ ចូររកថាមពលស៊ីនេទិចមធ្យមរបស់ម៉ូលេគុលនីមួយៗ(គិតជាអេឡិចត្រុង-វ៉ុល)របស់ម៉ូលេគុលអុកស៊ីសែនក្នុងខ្យល់នៅក្នុងបន្ទប់មានសីតុណ្ហភាព300K។

ចម្លើយ៦៖ រកថាមពលស៊ីនេទិចមធ្យមរបស់ម៉ូលេគុលឧស្ម័នអុកស៊ីសែន

តាម $K_{av}=\frac{3}{2}k_BT$

ដោយ $k_B=1.38\times10^{-23}J/K\,;T=300K$

$$\Rightarrow K_{av}=\frac{3}{2}\times1.38\times10^{-23}\times300$$

$=6.21\times10^{-21}J$

តែ $1eV=1.6\times10^{-19}J$

ដូចនេះ:$K_{av}=\frac{6.21\times10^{-21}}{1.6\times10^{-19}}=\boxed{0.039\ eV}$

## ជំពូក១ ទែម៉ូឌីណាមិច

### មេរៀនទី២៖ ច្បាប់ទីមួយ នៃទែម៉ូឌីណាមិច

ប្រព័ន្ធ គឺជាវត្ថុ ឬសំណុំវត្ថុដែលលើកយកមកសិក្សា បើធៀបនឹងវត្ថុដទៃ។

កាលណាប្រព័ន្ធមួយផ្លាស់ប្តូរភាពដោយប្តូរតែកម្មន្ត និងកម្តៅជាមួយមជ្ឈដ្ឋានក្រៅ គេថា ប្រព័ន្ធនោះទទួលបំលែងទែម៉ូឌីណាមិច។

បំលែងចំហគឺជាបំលែងដែល ប្រព័ន្ធផ្លាស់ប្តូរភាពដើមទៅភាពស្រេចណាមួយខុសពីមុន។

បំលែងបិទគឺជាបំលែងដែល ប្រព័ន្ធផ្លាស់ប្តូរភាពដើមទៅភាព ស្រេចណាមួយរួចត្រឡប់មករកភាពដើមវិញ។

លំនាំមួយចំនួនៗក្នុងបំលែងទែម៉ូឌីណាមិច

| លំនាំទែម៉ូឌីណាមិច | លក្ខណៈរបស់លំនាំ |
|---|---|
| អ៊ីសូករ | មាឌថេរ |
| អ៊ីសូបារ | សម្ពាធថេរ |
| អ៊ីសូទែម | សីតុណ្ហភាពថេរ |
| អាដ្យាបាទិច | គ្មានបណ្តូរកម្តៅ |

កម្មន្តក្នុងលំនាំមួយចំនួន

| លំនាំ | កម្មន្ត | ក្រាប $P$ $V$ |
|---|---|---|
| អ៊ីសូករ | ដោយក្នុងលំនាំអ៊ីសូករ មាឌឧស្ម័នថេរ នាំឱ្យ<br>កម្មន្ត $\boxed{W = 0}$ |  |
| អ៊ីសូបារ | កម្មន្តក្នុងលំនាំអ៊ីសូបារជាផ្ទៃឆ្នូតដូចក្នុងរូប<br>$\boxed{W = P(V_f - V_i)}$<br>$W$ជាកម្មន្តដែលឧស្ម័នធ្វើ គិតជា(J)។<br>$P_f$ជាសម្ពាធស្រេចរបស់ឧស្ម័ន $(Pa)$។<br>$P_i$ជាសម្ពាធដើមរបស់ឧស្ម័ន $(Pa)$។ |  |

| | | |
|---|---|---|
| | $V_f$ ជាមាឌស្រេចរបស់ឧស្ម័ន $m^3$។<br>$V_i$ ជាមាឌដើមរបស់ឧស្ម័ន $m^3$។ | |
| សម្ពាធប្រែប្រួល | កម្មន្តក្នុងលំនាំសម្ពាធប្រែប្រួលជាផ្ទៃឆ្នូតដូចក្នុងរូប<br>$W = W_1 + W_2$<br>✓ $W_1 = P_i(V_f - V_i)$<br>✓ $W_2 = \frac{1}{2}(P_f - P_i)(V_f - V_i)$<br>$W = P_i(V_f - V_i) + \frac{1}{2}(P_f - P_i)(V_f - V_i)$ |  |
| អ៊ីសូទែម | កម្មន្តក្នុងលំនាំអ៊ីសូទែម<br>($T$ ថេរ) ជាផ្ទៃឆ្នូតដូចក្នុងរូប<br>$W = nRT\ln\left(\frac{V_f}{V_i}\right)$<br>$n$ ជាចំនួនម៉ូលឧស្ម័ន($mol$)។<br>$R$ ជាថេរសកលនៃឧស្ម័ន។<br>$T$ ជាសីតុណ្ហភាពរបស់ឧស្ម័ន ($K$)។ |  |

ច្បាប់ទីមួយ ទែម៉ូឌីណាមិច ៖ ក្នុងបំលែងទែម៉ូឌីណាមិច កម្តៅស្រូបដោយប្រព័ន្ធ ស្មើនឹងផលបូកកម្មន្តដែលបានបង្កើតឡើងដោយប្រព័ន្ធ និងបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ។

$$Q = \Delta U + W$$

$Q$ ជាកម្តៅស្រូបដោយប្រព័ន្ធគិតជា(J), $\Delta U$ ជាបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធគិតជា(J), $W$ ជាកម្មន្តដែលបានបង្កើតឡើងដោយប្រព័ន្ធគិតជា(J)

សិក្សាសញ្ញា របស់ $Q$, $W$ និង $\Delta U$

| អញ្ញាត | សញ្ញា | អត្ថន័យ |
|---|---|---|
| $Q$ | $+$ | កាលណាប្រព័ន្ធទទួលកម្តៅ។ |
| $Q$ | $-$ | កាលណាប្រព័ន្ធបំភាយកម្តៅ*ទៅ*មជ្ឈដ្ឋានក្រៅ។ |
| $W$ | $+$ | កាលណាឧស្ម័នក្នុងប្រព័ន្ធធ្វើកម្មន្តដោយខ្លួនឯង។ |

| | | |
|---|---|---|
| $W$ | $-$ | កាលណាឧស្ម័នក្នុងប្រព័ន្ធទទួលកម្លាំងពីមជ្ឈដ្ឋានក្រៅដើម្បីធ្វើកម្មន្ត។ |
| $\Delta U$ | $+$ | មានន័យថាថាមពលក្នុងកើនឡើង។ |
| $\Delta U$ | $-$ | មានន័យថាថាមពលក្នុងថយចុះ។ |

ច្បាប់ទីមួយ ទែម៉ូឌីណាមិច ចំពោះលំនាំពិសេសៗបី

| លំនាំ | លក្ខណៈរបស់លំនាំ | លទ្ធផល |
|---|---|---|
| អាដ្យាបាទិច | $Q = 0$ | $\Delta U = -W$ |
| អ៊ីសូករ | $W = 0$ | $\Delta U = Q$ |
| បំលែងបិទ | $\Delta U = 0$ | $Q = W$ |

ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធគឺជាថាមពលស៊ីនេទិចសរុបរបស់ម៉ូលេគុលនៃឧស្ម័ននោះ។

ថាមពលក្នុង $n$ម៉ូល នៃឧស្ម័នបរិសុទ្ធម៉ូណូអាតូម $U = \frac{3}{2}nRT$

$U$ ជាថាមពលក្នុងគិតជា(J), $n$ជាចំនួនម៉ូលរបស់ឧស្ម័ន$(mol)$, $T$ជាសីតុណ្ហភាពរបស់ឧស្ម័ន $(K)$, $R$ ជាថេរសកលនៃឧស្ម័ន$R = 8.31J/(mol.K)$

បម្រែបម្រួលថាមពលក្នុង $n$ម៉ូល នៃឧស្ម័នបរិសុទ្ធម៉ូណូអាតូម

$$\Delta U = \frac{3}{2}nR\Delta T = \frac{3}{2}nR\left(T_f - T_i\right)$$

$\Delta U$ជាបម្រែបម្រួលថាមពលក្នុងនៃឧស្ម័នបរិសុទ្ធម៉ូណូអាតូម គិតជា(J)

$T_f$ ជាសីតុណ្ហភាពស្រេចរបស់ឧស្ម័ន គិតជា$(K)$

$T_i$ ជាសីតុណ្ហភាពដើមរបស់ឧស្ម័ន គិតជា$(K)$

**ឧទាហរណ៍១៖** តើផ្ទៃដែលបានគូសក្នុងដ្យាក្រាម P-V ស្មើប៉ុន្មាន? តើកម្មន្តដែលបានធ្វើពីភាព $A \rightarrow B$ ស្មើប៉ុន្មាន? $P$=2atm



**ចម្លើយ១៖** តាមផ្ទៃនៃរូបជាផ្ទៃចតុកោណកែង

$$S = \text{ទទឹង} \times \text{បណ្ដោយ}$$

ទទឹង $= 2atm = 2 \times 10^5 Pa$

បណ្ដោយ $= (4-2)\ell = 2\ell = 2 \times 10^{-3} m^3$

$\Rightarrow S = 2 \times 10^5 \times 2 \times 10^{-3} = 4 \times 10^2\, J$

កម្មន្តពីភាព A ទៅភាព B (ជាលំនាំអ៊ីសូបារ)

$W = P\Delta V = P(V_B - V_A)$

ដោយ $P = 2atm = 2 \times 10^5 Pa;\ V_B = 4 \times 10^{-3} m^3;$

$V_A = 2 \times 10^{-3} m^3$

$\Rightarrow W = 2 \times 10^5 (4 \times 10^{-3} - 2 \times 10^{-3}) = 4 \times 10^2 J$

ដូចនេះកម្មន្តពីភាពAទៅភាពBគឺស្មើផ្ទៃរបស់រូប។

**ឧទាហរណ៍២៖** គណនាកម្មន្តសរុបក្នុងបំលែងបិទABC?




**ចម្លើយ២៖** រកកម្មន្តក្នុងបំលែងបិទABC

$$W_{ABC} = W_{AB} + W_{BC} + W_{CA}$$

រក$W_{AB}$

$$W_{AB} = P_A(V_B - V_A) + ½\,(P_B - P_A)(V_B - V_A)$$

ដោយ$P_A = 2atm\ 2\times10^5 Pa$

$P_B = 1atm = 10^5 Pa$

$V_B = 5m^3,\ V_A = 2m^3$

$\Rightarrow W_{AB} = 2\times10^5(5-2) + ½\,(10^5 - 2\times10^5)\,(5-2)$

$= 4.5\times10^5\ J$

រក$W_{BC}$

$$W_{BC} = P_B\,(V_C - V_B) = 10^5(2-5) = -\,3\times10^5 J$$

រក$W_{CA}$ (ជាលំនាំអ៊ីសូករ)

$$W_{CA} = 0$$

ដូចនេះ $W_{ABC} = (4.5\times10^5 J) - (3\times10^5 J) + 0 = 1.5\times10^5 J$

**ឧទាហរណ៍៣៖** ឧស្ម័នបរិសុទ្ធមួយធ្វើបំលែងជាបំលែងបិទពីភាព A ទៅភាព B រួចទៅភាព C ហើយ ទៅភាព D ទៀតក្រោយមកត្រឡប់ទៅភាពAវិញដូចបានបង្ហាញក្នុងរូប។គណនា

ក.កម្មន្តAB, BC, CD, DA

ខ.កម្មន្តសរុបក្នុងបំលែងបិទ

គ.កម្តៅដែលទទួលបាន(ក្នុងបំលែងបិទ)។




**ចម្លើយ៣៖**ក.គណនាកម្មន្ត AB, BC, CD, DA

កម្មន្តពីភាពAទៅភាពB(លំនាំអ៊ីសូបារ)

$W_{AB}= P_A(V_B-V_A)$ដោយ$P_A=2\times10^5Pa$;

$V_B=2.5\times10^{-3}m^3$; $V_A=10^{-3}m^3$

$\Rightarrow W_{AB}=2\times10^5(2.5\times10^{-3}-10^{-3}) = 3\times10^2$ J

កម្មន្តពីភាព$B$ ទៅភាព$C$ (លំនាំអ៊ីសូករ)

$W_{BC}= 0$

កម្មន្តពីភាពCទៅភាពD(លំនាំអ៊ីសូបារ)

$W_{CD}= P_C(V_D-V_C)$ ដោយ$V_D=10^{-3}m^3$,

$V_C=2.5\times10^{-3}m^3$; $P_C=1atm=10^{-5}Pa$

$\Rightarrow W_{AB}=10^5(10^{-3}-2.5\times10^{-3}) = -1.5\times10^2$ J

កម្មន្តពីភាពDទៅភាពA (លំនាំអ៊ីសូករ)

$W_{DA}= 0$

ខ. កម្មន្តសរុបក្នុងបំលែងបិទ

$W_{ABCD}=W_{AB}+W_{BC}+W_{CD}+W_{DA}$

$= 3\times10^2 + 0 - 1.5\times10^2 + 0 = 150$ J

ដូចនេះ$W_{ABCD}= 150$ J

គ. កម្តៅដែលឧស្ម័នទទួលបាន

តាមច្បាប់ទីមួយទែម៉ូឌីណាមិច $Q = \Delta U + W$ដោយបំលែងជាបំលែងបិទនាំឲ្យ $\Delta U = 0$

ដូចនេះ $Q = W = 150 J$

**ឧទាហរណ៍៤៖** គេធ្វើកម្មន្ត25kJ លើប្រព័ន្ធឧស្ម័ន។ក្រោយមកកម្តៅ1 5kcal បានភាយចេញពីប្រព័ន្ធ។ គណនាបម្រែបម្រួលថាមពលក្នុង។ ( $1cal = 4.186J$)

**ចម្លើយ៤៖** គណនាបម្រែបម្រួលលថាមពលក្នុង

តាមច្បាប់ទី1ទែម៉ូឌីណាមិច$Q = \Delta U + W \Rightarrow \Delta U = Q - W$

ដោយ$Q = -1.5kcal = -62.7 \times 10^3 J;$

W= -25kJ = -25×10³J

$\Rightarrow \Delta U = -62.7 \times 10^3 - (-25 \times 10^3)$

$= -37.7 \times 10^3 J$

ដូចនេះ$\Delta U = -37.7 \times 10^3 J$

**ឧទាហរណ៍៥៖** មួយម៉ូលនៃឧស្ម័ន$O_2$ (សន្មតថាវាជាឧស្ម័នបរិសុទ្ធ) ។

ក.ឧស្ម័នរីកនៅសីតុណ្ហភាពថេរT=300K ពីមាឌដើម $V_i$=12 $l$ទៅ$V_f$=19 $l$។គណនាកម្មន្តក្នុងដំណើរការរីករបស់ឧស្ម័ន។

ខ.ឧស្ម័នរួមមាឌនៅសីតុណ្ហភាពថេរT=310K ពីមាឌ$V_i$=19 $l$ទៅ$V_f$= 12 $l$។គណនាកម្មន្តក្នុងដំណើរការរួមមាឌ។

**ចម្លើយ៥៖**

ក.កម្មន្តក្នុងដំណើរការពង្រីក

ដោយT=ថេរនោះវាជាលំនាំអ៊ីសូទែម

$$W = nRTln\left(\frac{V_f}{V_i}\right) \text{ ដោយ } R = 8.31 J/mol\,K$$

n=1mol, T=310K, $V_f = 19l, V_i = 12l$

$\Rightarrow W = 1 \times 8.31 \times 310ln\left(\frac{19}{12}\right) = 1183J$

ខ.កម្មន្តក្នុងដំណើរការបង្រួម

$W = nRTln\left(\frac{V_f}{V_i}\right)$ ដោយ $R = 8.31 J/mol\,K$

n=1mol, T=310K, $V_f = 19l, V_i = 12l$

$\Rightarrow W = 1 \times 8.31 \times 310ln\left(\frac{12}{19}\right) = -1183J$

**ឧទាហរណ៍៦៖** ក្នុងប្រព័ន្ធទែម៉ូឌីណាមិចប្រព័ន្ធទទួលកម្មន្ត200Jនិងទទួលកម្តៅ500J។ រកបម្រែបម្រួលថាមពលក្នុង?

**ចម្លើយ៦៖** គណនាបម្រែបម្រួលថាមពលក្នុង

តាមច្បាប់ទី1ទែម៉ូឌីណាមិច

$Q = \Delta U + W \Rightarrow \Delta U = Q - W$

ដោយQ=+500J ប្រព័ន្ធទទួលកម្តៅ

W=–200J ប្រព័ន្ធទទួលកម្មន្ត

$\Rightarrow \Delta U = 500J + 200J = 700J$

ដូចនេះបម្រែបម្រួលថាមពលក្នុងគឺ$700J$

## ជំពូក១ ទែម៉ូឌីណាមិច

## មេរៀនទី៣៖ ម៉ាស៊ីន

ម៉ាស៊ីនកម្ដៅ




$Q_h$: បរិមាណកម្ដៅបានពីប្រភពក្ដៅផ្ដល់ឱ្យម៉ាស៊ីន(ថាមពលសរុប)គិតជាស៊្សូល(J)

$W$ : កម្មន្តដែលឧស្ម័នធ្វើ (បានការ) គិតជាស៊្សូល (J)

$Q_C$: បរិមាណកម្ដៅដែលបំភាយទៅ ប្រភពត្រជាក់ឬមជ្ឈដ្ឋានក្រៅ (បរិមាណកម្ដៅមិនបានការ) គិតជាស៊្សូល (J)

- ❖ តុល្យការថាមពល $Q_h = Q_c + W$
- ❖ ទិន្នផលកម្ដៅនៃម៉ាស៊ីន $e_c = \frac{W}{Q_h}$
- ❖ កម្មន្តដែលឧស្ម័នធ្វើ $W = Q_h - Q_c$
- ❖ ទិន្នផលកម្ដៅនៃម៉ាស៊ីន $e_c = \frac{W}{Q_h} = \frac{Q_h - Q_c}{Q_h} = 1 - \frac{Q_c}{Q_h}$

ទ្រឹស្តីបទ កាកណូ ៖ បើម៉ាស៊ីនមួយដំណើរការរវាងធុងពីរ ដែលមានសីតុណ្ហភាពថេរមានទិន្នផលអតិបរិមា ហើយដំណើរនេះមានភាពវេស៊ីប ហើយម៉ាស៊ីនទាំងអស់ដំណើរការនៅចន្លោះសីតុណ្ហភាពដូចគ្នា មានទិន្នផលដូចគ្នា

$$e_c = 1 - \frac{Q_c}{Q_h} = 1 - \frac{T_c}{T_h}$$

$T_c$ ជាសីតុណ្ហភាពប្រភពត្រជាក់ គិតជា $(K)$

$T_f$ ជាសីតុណ្ហភាពប្រភពក្ដៅ គិតជា $(K)$

ម៉ូទ័រប៉ុន្មានដែរ? ប៊ូនវគ្គ៖ វគ្គស្រូប វគ្គបណ្ដែន វគ្គបន្ទុះនិងបន្ធូរ វគ្គបញ្ចេញ។
ម៉ាស៊ីនម៉ូទ័រ




- តុល្យការថាមពល

$$\boxed{Q_h = W_M + Q_C}$$

$$\boxed{W_M = W_U + Q}$$

$W_M$ ជាកម្មន្តមេកានិចគិតជាស៊្សូល(J),$W_U$ ជាកម្មន្តបានការ គិតជាស៊្សូល (J),

$Q_C$ បរិមាណកម្តៅដែលបំភាយទៅ ប្រភពត្រជាក់ឬមជ្ឈដ្ឋានក្រៅ (បរិមាណកម្តៅមិនបានការ)គិតជាស៊្សូល(J)

$Q$ បរិមាណកម្តៅដែលបាត់បង់ដោយសារកកិត (បរិមាណកម្តៅមិនបានការ) គិតជាស៊្សូល (J)

- ទិន្នផលកម្តៅនៃម៉ាស៊ីន $\boxed{e_C = \dfrac{W_M}{Q_h}}$

- ទិន្នផលគ្រឿងបញ្ជូន ឬទិន្នផលមេកានិច $\boxed{e_M = \dfrac{W_U}{W_M}}$

- ទិន្នផលបានការនៃម៉ាស៊ីន

$$\boxed{e = \frac{W_U}{Q_h} = \frac{W_U}{W_M} \times \frac{W_M}{Q_h} = e_M \times e_C}$$

ម៉ាស៊ីនម៉ាស៊ូត មានទិន្នផលខ្ពស់ជាងម៉ាស៊ីនសាំង។

**ឧទាហរណ៍១៖** ម៉ាស៊ីនកម្តៅស្រូបកម្តៅ200J ពីប្រភពក្តៅដើម្បីធ្វើកម្មន្តនិងបំភាយកម្តៅ160J ទៅប្រភពត្រជាក់។ គណនាទិន្នផលកម្តៅនៃម៉ាស៊ីន។

**ចម្លើយ១៖** គណនាទិន្នផលកម្តៅនៃម៉ាស៊ីន

$e_c = \dfrac{W}{Q_h}$ តែដោយ $Q_h = W + Q_C$

$\Rightarrow W = Q_h - Q_C$ ដូចនេះ $e_c = \dfrac{Q_h - Q_C}{Q_h}$

$= 1 - \frac{Q_C}{Q_h}$ ដោយ $Q_C = 160J$ ; $Q_h = 200J$

$$e_c = 1 - \frac{160}{200} = 0.2 = 20\%$$

**ឧទាហរណ៍២៖** ម៉ាស៊ីនមួយមានទិន្នផលកម្ដៅ35%ចូរគណនា

ក. គណនាកម្មន្តដែលបានធ្វើក្នុងមួយខួបប្រសិនបើវាស្រូបកម្ដៅ150J ក្នុងមួយខួបពីប្រភពក្ដៅ។

ខ. តើមានកម្ដៅភាយចេញប៉ុន្មាន?

**ចម្លើយ២៖** ក.គណនាកម្មន្តដែលបានធ្វើក្នុងមួយខួប

តាមទិន្នផលកម្ដៅ $e_c = \frac{W}{Q_h}$

$\Rightarrow$ $W = e_c \times Q_h$

ដោយ $Q_h = 150J; e_c = 0.35$

$W = 0.35 \times 150 = 52.5J$

ខ. គណនាកម្ដៅ$Q_C$

តាមតុល្យការថាមពល

$$Q_h = W + Q_C \Rightarrow Q_C = Q_h - W$$
$$Q_C = 150J - 52.5J = 97.5J$$

**ឧទាហរណ៍៣៖** ម៉ាស៊ីនកាកណូធ្វើការរវាងប្រភពកម្ដៅពីរនៅ500K និង300K។

ក. រកទិន្នផលកម្ដៅនៃម៉ាស៊ីនកាកណូ។

ខ. ប្រសិនបើវាបំភាយកម្ដៅ200Jពីប្រភពក្ដៅ។ចូររកកម្មន្តដែលធ្វើវា។

**ចម្លើយ៣៖** ក.រកទិន្នផលកម្ដៅនៃម៉ាស៊ីនកាកណូ

តាម $e_c = 1 - \frac{Q_C}{Q_h}$ តែ $\frac{Q_C}{Q_h} = \frac{T_C}{T_h} \Rightarrow e_c = \frac{T_C}{T_h}$

ដោយ $T_C=300K; T_h=500K$

$$e_c = \frac{300}{500} = 0.4 = 40\%$$

ខ. គណនាកម្មន្ត

តាម $e_c = \frac{W}{Q_h} \Rightarrow W = e_c \times Q_h$

ដោយ $Q_h=200kJ; e_c = 0.4$

$\Rightarrow$ $W = 0.4 \times 200 = 80kJ$

**ឧទាហរណ៍៤៖** ម៉ាស៊ីនពិតធ្វើការក្នុងចន្លោះរវាងប្រភពកម្ដៅពីររវាង 500K និង 300K។ វាបំភាយកម្ដៅ 500kJ ពីប្រភពក្ដៅនិងធ្វើកម្មន្ត150kJ ក្នុងរាល់ខួប។ រកទិន្នផលនៃម៉ាស៊ីន?

**ចម្លើយ៤៖** រកទិន្នផលកម្ដៅនៃម៉ាស៊ីនពិត

តាម$e_c = \frac{W}{Q_h}$ ដោយ$W = 150kJ$; $Q_h = 500kJ$

$e_c = \frac{150}{500} = 0.3$ ដូចនេះ$e_c$= 30%



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

ចំណាំៈ យើងមិនអាចប្រើរូបមន្ត$e_c = 1 - \frac{T_C}{T_h}$ព្រោះវាជារូបមន្ត ទិន្នផលកម្តៅនៃម៉ាស៊ីនវេរបេស៊ីបមិនមែនម៉ាស៊ីនពិតទេ។

**ឧទាហរណ៍៥ៈ** ម៉ាស៊ីនកាកណូដែលមានប្រភពត្រជាក់$T_C = 7^0C$ហើយមានទិន្នផលកម្តៅ50%។ ម៉ាស៊ីននេះមានទិន្នផលកម្តៅកើនឡើងដល់70%។តើសីតុណ្ហភាពនៃប្រភពក្តៅកើនឡើងបានប៉ុន្មានដឺក្រេ?

**ចម្លើយ៥ៈ** រកកំណើនសីតុណ្ហភាព $\Delta T_h$ (នៅប្រភពក្តៅ)

ក្នុងករណីដំបូង

$$e_c = 1 - \frac{T_C}{T_h} \Rightarrow \frac{T_C}{T_h} = 1 - e_c$$

$$\Rightarrow T_h = \frac{T_C}{1 - e_c}$$

ដោយ $T_C = 7^0C$=280 $K$,$e_c$=0.5

$$T_h = \frac{280}{1-0.5} = 560K$$

ក្នុងករណីស្រេច

$$e_c' = 1 - \frac{T_C}{T_h'} \Rightarrow T_h' = \frac{T_C}{1 - e_c'}$$

ដោយ $e_c' = 0.7$

$$T_h' = \frac{280}{1-0.7} = 933.33K$$

$$\Delta T_h = T_h' - T_h = 933.33 - 560 = 373.33\ K$$

**ឧទាហរណ៍៦ៈ** ម៉ូទ័រម៉ាស៊ីនម៉ាសូតនៃរថយន្តមួយដែលទិន្នផលកម្តៅ0.43ហើយវាស្រូបបរិមាណកម្តៅ 4MJ។

ក.គណនាកម្មន្តមេកានិចដែលបានពីពីស្តុង

ខ.គណនាបរិមាណកម្តៅដែលបញ្ចេញទៅក្នុងបរិយាកាស។

គ.គណនាកម្មន្តបានការបើគេដឹងថាទិន្នផលគ្រឿងបញ្ជូន0.82។

**ចម្លើយ៦ៈ** ក. គណនាកម្មន្តមេកានិច

ទិន្នផលកម្តៅ $$e_C = \frac{W_M}{Q_h}$$

$$\Rightarrow W_M = e_C \times Q_h$$

ដោយ $Q_h = 4MJ = 4 \times 10^6 J$ ; $e_C = 0.43$

$$W_M = 0.43 \times (4 \times 10^6) = 1.72 \times 10^6 J$$

ខ. គណនាបរិមាណកម្តៅដែលបំភាយចេញ

តាមតុល្យការថាមពល

$$Q_h = W_M + Q_C \Rightarrow Q_C = Q_h - W_M$$

$$Q_C = 4 \times 10^6 - 1.72 \times 10^6 = 2.28 \times 10^6 J$$

គ. គណនាកម្មន្តបានការ

ទិន្នផលគ្រឿងទទួល$e_M = \frac{W_U}{W_M}$

$$\Rightarrow W_U = e_M \times W_M$$

ដោយ $e_M = 0.82$ ;$W_M = 1.72 \times 10^6 J$

$$W_U = 0.82 \times 1.72 \times 10^6 J = 1.41 \times 10^6 J$$

# ជំពូក២ រលក

## មេរៀនទី១៖ គោលការណ៍តម្រួតនៃរលក និងរលកជញ្រ្ជំ

គោលការណ៍តម្រួតកាលណារលកពីរឬច្រើនដាលឆ្លងកាត់មជ្ឈដ្ឋានតែមួយបម្លាស់ទីសរុបនៃរាល់ចំណុចណាក៏ដោយនៃរលកស្មើនិងផលបូកវ៉ិចទ័រនៃបណ្តាលចំណុចបម្លាស់ទីរលកទោលទាំងនោះ រលកបែបនេះហៅថារលកលីនេអែរឬរលកតម្រួត។

សំណង់ប្រេណែល

យើងបានឃើញរួចមកហើយពីសមីការនៃចលនាស៊ីនុយសូអ៊ីតក្នុងចលនារំកិល និង ចលនារង្វិលដែលមានរាង៖ $y = a\,Sin(\omega t+\phi)$

$y$: ជាអេឡុងកាស្យុង$(m)$ ; $(\omega t+\phi)$: ជាផាសនៅខណៈ$t$

$a$ :ជាអំព្លីទុត$(m)$; $\omega$ : ជាពុលសាស្យុង$(rad/s)$ ; $\phi$ : ជាផាសដើម$(rad)$ ។

ដើម្បីសម្រួលក្នុងការសិក្សាចលនាស៊ីនុយសូអ៊ីត ត្រូវបានតាងដោយវ៉ិចទ័រ $\overrightarrow{OA}$មួយដែលគេកំណត់ដូចខាងក្រោម៖

- ទិស : បង្កើតបានមុំ$(\omega t+\phi)$ធៀបទៅនឹងអ័ក្សណាមួយដែលគេជ្រើសរើសជាគល់នៃផាសដើម ។
- គល់ : ចំណុច o ណាមួយនៅលើអ័ក្ស ។
- ម៉ូឌុល : អំព្លីទុតនៃចលនា ។




ករណីពិសេស




ចលនាពីរស្របផាសគ្នា

(ផលសងផាស$\Delta\phi = 0$ )




ចលនាពីរផាសឈមគ្នា

(ផលសងផាស$\Delta\phi = \pi$ )




ចលនាពីរខ្វែងផាសគ្នា

(ផលសងផាស$\Delta\phi = \frac{\pi}{2}$)

ផលបូកអនុគមន៍ស៊ីនុយសូអ៊ីតពីរ

ឧបមាថា ចំណុច M ណាមួយទទួលនៅពេលជាមួយគ្នានូវចលនាស៊ីនុយសូអ៊ីតពីរ ដែលមានទិស , ខួប , ប្រេកង់ និងជំហានរលកដូចគ្នា តែផាសខុសគ្នា នាំឱ្យយើងអាចសរសេរ៖

$$y_1 = a_1\,Sin(\omega t+\phi_1) \text{ និង } y_2 = a_2\,Sin(\omega t+\phi_2)$$

តាមគោលការណ៍តម្រួត $y = y_1 + y_2 = a\,Sin(\omega t + \phi)$

- ផលសងផាស $\Delta\phi = \phi_2 - \phi_1$
- អំព្លីទុត $a = \sqrt{a_1^2 + a_2^2 + 2a_1 a_2 cos(\phi_2 - \phi_1)}$
- ផាសដើមរបស់រលកតម្រួត

$$tan\phi = \frac{a_1 sin\phi_1 + a_2 sin\phi_2}{a_1 cos\phi_1 + a_2 cos\phi_2}$$

ផលបូកអនុគមន៍ស៊ីនុយស្វអ៊ីតច្រើនជាងពីរ

ឧបមាថាចំណុច M ណាមួយទទួលនៅពេលជាមួយគ្នានូវ n ចលនាស៊ីនុយស្វអ៊ីតដែលមានប្រេកង់, ជំហានរលកនិងខួប $T = \frac{2\pi}{\omega}$ដូចគ្នាតែផាសខុសគ្នាគឺ

$$y_1 = a_1 \sin(\omega t + \phi_1)$$
$$y_2 = a_2 \sin(\omega t + \phi_2)$$
........................
........................
$$y_n = a_n \sin(\omega t + \phi_n)$$

- តាមគោលការណ៍តម្រួតនៃរលកយើងបាន៖

$$y = y_1 + y_2 + y_3 + \cdots + y_n = a\,Sin(\omega t + \phi)$$

- អំព្លីទុត $a = \sqrt{a_x^2 + a_y^2}$

ដែល $a_x = a_1 cos\phi_1 + a_2 cos\phi_2 + \cdots + a_n cos\phi_n$

និង $a_y = a_1 sin\phi_1 + a_2 sin\phi_2 + \cdots + a_n sin\phi_n$

- ផាសដើមរបស់រលកតម្រួត $tan\phi = \frac{a_y}{a_x}$

រលកជញ្ជ្រំ៖ បើរលកស៊ីនុយសូអ៊ីត 2 ដែលមានអំព្លីទុតនិងជំហានរលកដូចគ្នាផ្លាស់ទីតាមទិសដៅផ្ទុយគ្នាតម្រួតនៃរលកទាំង 2 នោះបង្កើតបានជារលកជញ្ជ្រំ។




(a) $t = 0$ (b) $t = T/4$ (c) $t = T/2$




Antinode (A) ជាពោះ និង Node (N) ជាថ្នាំង

យើងតាង អនុគមន៍រលកទីមួយដាលពីឆ្វេងទៅស្តាំ $y_1 = A\sin(kx - \omega t)$ និងអនុគមន៍រលកទីមួយដាលពីស្តាំទៅឆ្វេង $y_2 = A\sin(kx + \omega t)$។នៅពេលត្រួតរលកទាំងពីរ គេបាន

$$y = y_1 + y_2 = A\sin(kx - \omega t) + A\sin(kx + \omega t) = A[\sin(kx - \omega t) + A\sin(kx + \omega t)]$$

ដោយប្រើរូបមន្ត $\sin(a + b) = 2\sin\left(\frac{a+b}{2}\right)\cos\left(\frac{a-b}{2}\right)$

ដូចនេះ៖

- ទីតាំងពោះរបស់រលកជញ្ជ្រំ
  ត្រង់ទីតាំងពោះមានន័យថា តម្លៃ $2Asinkx$ អតិបរិមា
  គេបាន $$sinkx = \pm 1$$
  $$\Rightarrow kx = \frac{\pi}{2}, \frac{3\pi}{2}, \frac{5\pi}{2}, \ldots$$

$\Rightarrow x = \frac{\lambda}{4}, \frac{3\lambda}{4}, \frac{5\lambda}{4}, \ldots = n\frac{\lambda}{4}$ ជាទីតាំងពោះ ( អំព្លីទុតអតិបរមា)ដែល$n = 1,3,5,7 \ldots$

- ទីតាំងថ្នាំងរបស់រលករលកជញ្ជ្រំ
  ត្រង់ទីតាំងថ្នាំងមានន័យថា តម្លៃ $2Asinkx = 0$
  គេបាន $$sinkx = 0$$
  $$\Rightarrow kx = 0, \pi, 2\pi, 3\pi \ldots$$

$\Rightarrow x = 0, \frac{\lambda}{2}, \lambda, \frac{3\lambda}{2}, \ldots = n\frac{\lambda}{2}$ ជាទីតាំងថ្នាំង (អំព្លីទុតស្មើសូន្យ) ដែល$n = 0,1,2,3,4, \ldots$

**ឧទាហរណ៍១៖** បម្លាស់ទីនៃរលកមួយឲ្យដោយសមីការ$y = 0.1Sin(0.1x - 0.1t)(m)$
គណនាអំព្លីទុតនៃរលក ចំនួនរលក ជំហានរលក ខួបនៃរលក និងល្បឿនដំណាលរលក។

**ចម្លើយ១៖** យើងមានសមីការរាង$y = Asin(kx - \omega t)$

អំព្លីទុតនៃរលក $A = 0.1m$ , ចំនួនរលក$k = 0.1/m,$

ជំហានរលក $\lambda = \frac{2\pi}{k} = \frac{2\pi}{0.1} = 20\pi\ m$ , ខួបនៃរលក$T = \frac{2\pi}{\omega} = \frac{2\pi}{0.1} = 20\pi\ s$

ល្បឿនដំណាលរលក $v = \frac{\lambda}{T} = \frac{20\pi}{20\pi} = 1m/s$

**ឧទាហរណ៍២៖** ចូរគណនាប្រេកង់ និងល្បឿនដំណាលរលក ដែលសមីការរលកឱ្យដោយ

$$y = 0.6Sin2\pi\left(\frac{x}{55} - \frac{t}{0.05}\right)(m)$$

**ចម្លើយ២៖** យើងមានសមីការរាង$y = Asin(kx - \omega t)$

ប្រេកង់$f = \frac{1}{T} = \frac{\omega}{2\pi} = \frac{1/0.55}{2\pi} = \frac{1}{`1.1\pi}Hz$

ល្បឿនដំណាលរលក$v = \frac{2\pi/k}{2\pi/\omega} = \frac{\lambda}{T} = \frac{\omega}{k} = \frac{1/0.05}{1/55} = \frac{55}{0.05} = 1100m/s$

**ឧទាហរណ៍៣៖** រករលកតម្រូតនៃលំយោល

ក$y_1 = 4Sin\left(5\pi t + \frac{\pi}{6}\right)(cm)$

$y_2 = 6Sin\left(5\pi t + \frac{\pi}{2}\right)(cm)$

ខ$y_1 = 7Sin(10\pi t)(cm)$

$y_2 = 8Sin\left(10\pi t + \frac{\pi}{2}\right)(cm)$

$y_3 = 9Sin\left(10\pi t - \frac{\pi}{2}\right)(cm)$

ចម្លើយ៧៖ ក.តាមគោលការណ៍តម្រួត

- អំព្លីទុត $a = \sqrt{a_1^2 + a_2^2 + 2a_1a_2cos(\phi_2 - \phi_1)}$

$$= \sqrt{4^2 + 6^2 + 2 \times 4 \times 6\cos\left(\frac{\pi}{6} - \frac{\pi}{2}\right)} = 8.71m$$

- ផាស $tan\phi = \frac{a_1sin\phi_1 + a_2sin\phi_2}{a_1cos\phi_1 + a_2cos\phi_2} = \frac{4sin\frac{\pi}{6} + 6sin\frac{\pi}{2}}{4cos\frac{\pi}{6} + 6cos\frac{\pi}{2}} = 2.3$

$$\phi = tan^{-1}(2.3) = 66.50°$$

ខ.តាមគោលការណ៍តម្រួត

- $a_x = a_1cos\phi_1 + a_2cos\phi_2 + a_3cos\phi_3 = 7cos0 + 8cos\frac{\pi}{2} + 9\cos\left(-\frac{\pi}{2}\right) = 7$
- $a_y = a_1sin\phi_1 + a_2sin\phi_2 + a_3sin\phi_3 = 7sin0 + 8sin\frac{\pi}{2} + 9\,sin\left(-\frac{\pi}{2}\right) = -1$
- អំព្លីទុត$a = \sqrt{a_x^2 + a_y^2} = \sqrt{7^2 + (-1)^2} = 7.07cm$
- ផាសដើមរបស់រលកតម្រួត$tan\phi = \frac{a_y}{a_x}$

$$\phi = tan^{-1}\left(\frac{a_y}{a_x}\right) = tan^{-1}\left(\frac{-1}{7}\right) = -8.13°$$

**ឧទាហរណ៍៨៖** រលកពីរដាលក្នុងទិសដៅផ្ទុយគ្នាបង្កើតជារលកជញ្ជ្រុំ។សមីការរលកនីមួយៗ

$y_1 = (4.0m)Sin(3.0x - 2.0t)$

$y_2 = (4.0m)Sin(3.0x + 2.0t)$ដែល $x, y$ គិតជា(cm), $t$គិតជា$s$

ក. គណនាបម្លាស់ទីអតិបរិមានៅខណ:ដែល $x = 2.3cm$។

ខ. រកទីតាំងពោះ និងទីតាំងថ្នាំងនៃរលកជញ្ជ្រុំ។

**ចម្លើយ៨៖** ក. គណនាបម្លាស់ទីអតិបរិមានៅខណ:ដែល $x = 2.3cm$

$$y = y_1 + y_2 = Asin(kx - \omega t) + Asin(kx + \omega t)$$
$$y = A[sin(kx - \omega t) + Asin(kx + \omega t)] = (2Asinkx)cos\omega t$$

បម្លាស់ទីអតិបរិមា$y_m = (2Asinkx) = 2 \times 4\sin(3 \times 2.3rad) = 4.6 \quad cm$

ខ. រកទីតាំងពោះ និងទីតាំងថ្នាំងនៃរលកជញ្ជ្រុំ

ជំហានរលក $\lambda = \frac{2\pi}{k} = \frac{2\pi}{3}(cm)$

- ទីតាំងពោះ:$x = \frac{\lambda}{4}, \frac{3\lambda}{4}, \frac{5\lambda}{4}, \ldots. = \frac{2\pi}{12}, \frac{6\pi}{12}, \frac{10\pi}{12} \ldots, (cm)$
- ទីតាំងថ្នាំង $x = 0, \frac{\lambda}{2}, \lambda, \frac{3\lambda}{2}, \ldots. = 0, \frac{2\pi}{6}, \frac{2\pi}{3}, \frac{6\pi}{6}, \ldots\ (cm)$

# ជំពូក៣ អគ្គិសនីនិងម៉ាញេទិច

## មេរៀនទី១៖ ដែននិងកម្លាំងម៉ាញេទិច

មេដែក មានប៉ូលពីរ គឺ ប៉ូលជើង(N)និង ប៉ូលត្បូង (S)។
អន្តរកម្មម៉ាញេទិច គឺពេលមេដែកពីរមានប៉ូលដូចគ្នាដាក់ជិតគ្នាច្រានគ្នាចេញ ហើយពេលមេដែកពីរមានប៉ូលខុសគ្នាដាក់ជិតគ្នាទាញគ្នាចូល។
ប្រភពរបស់ដែនម៉ាញេទិចគឺ មេដែក ផែនដី និងចរន្តអគ្គិសនី។
មេដែកជា អង្គធាតុដែលអាចឆក់ដែកបាន។
មេដែកចែកចេញជាពីរគឺ មេដែកធម្មជាតិ (ដូចជាសំណាក $Fe_3O_4$) និងមេដែកសិប្បនិមិត្ត (មនុស្សបង្កើតឡើងដោយយករបារដែកថែបឬម្ជុលមេដែកថែបទៅបន្សុីឱ្យក្លាយជាមេដែក)។
មេដែកសិប្បនិមិត្ត មាន របារមេដែក ម្ជុលមេដែក និងមេដែករាង U ឬរាងក្រចកសេះ។ល។
ដែនម៉ាញេទិចនៃចរន្តត្រង់




- ករណីក្នុងខ្យល់ ឬសុញ្ញាកាល

$$B = \mu_o \frac{I}{2\pi d}$$

$B$ ជាដែនម៉ាញេទិចបង្កើតដោយចរន្តត្រង់ គិតជាតេស្លា($T$)
$d$ ជាចម្ងាយពីខ្សែចម្លងទៅចំនុច M គិតជា ($m$)
$I$ ជាអាំងតង់សុីតេចរន្តអគ្គិសនីឆ្លងកាត់ខ្សែចម្លងត្រង់គិតជាអំពែ ($A$)
$\mu_o$ ជាជំរាបម៉ាញេទិចនៃខ្យល់ ឬសុញ្ញាកាល$\mu_o = 4\pi \times 10^{-7}\ (T.m)/A$

- ករណីក្នុងមជ្ឈដ្ឋានណាមួយ

$B = \mu_o \mu_r \frac{I}{2\pi d}$

$\mu_r$ ជាជំរាបម៉ាញេទិចធៀបនៃមជ្ឈដ្ឋាន

ដែនម៉ាញេទិចនៃចរន្តវង់ (កាំ$R$)



- ករណីវង់មួយស្ពៀ $B = \mu_o \frac{I}{2R}$
  $R$ជាកាំរង្វង់នៃស្ពៀ គិតជា($m$)
  $I$ជាអាំងតង់សុីតេចរន្តអគ្គិសនីខ្សែចម្លងវង់គិតជា($A$)
- ករណីវង់$N$ ស្ពៀ $B = \mu_o \frac{NI}{2R}$
  $R$ជាកាំរង្វង់មធ្យមរបស់ស្ពៀ $N$ គិតជា($m$)

ដែនម៉ាញេទិចនៃសូលេណូអ៊ីត($\ell \geq 5R$ )

សូលេណូអ៊ីត(បូប៊ីនវែង)




- របៀបរកចំនួនស្ពៀN (តាមប្រវែងសូលេណូអ៊ីត$\ell$)

កររណីមិនគិតកម្រាស់អ៊ីសូឡង់ e ស្រោបខ្សែ

$\ell = N \cdot d$ =>

កររណីខ្សែស្រោបដោយអ៊ីសូឡង់e

$\ell = N(d + 2e)$ =>

B ដែនម៉ាញេទិចគិតជា (T) , I ចរន្តអគ្គិសនីគិតជា (A) ,
$R$ កាំសូលេណូអ៊ីតគិតជា (m)
D អង្កត់ផ្ចិតសូលេណូអ៊ីតគិតជា (m) , $\ell$ប្រវែងសូលេណូអ៊ីតគិតជា (m) ,
$N$ ចំនួនស្ពៀ, d អង្កត់ផ្ចិតខ្សែចម្លងគិតជា (m) ,$n$ជាចំនួនស្ពៀក្នុងមួយម៉ែត្រ

កម្លាំងអេឡិចត្រូម៉ាញេទិច៖ តាមការពិសោធបង្ហាញឱ្យឃើញថាកម្លាំងអេឡិចត្រូម៉ាញេទិចមាន

- ចំណុចចាប់ស្ថិតត្រង់ចំណុចកណ្ដាលនៃភាគខ្សែដែលស្ថិតក្នុងដែន។
- ទិសកែងនឹងប្លង់កំណត់ដោយវ៉ិចទ័រ $\vec{B}$និងចរន្ត $I$។
- ទិសដៅកំណត់តាមវិធានដៃស្តាំ (ដំបូងម្រាមទាំង4 លាទៅតាមទិសដៅចរន្ត$I$ ហើយម្រាមទាំង4 ក្ដោបមកតាមវ៉ិចទ័រ$\vec{B}$ នោះមេដៃកន្ទេកឱ្យកែងនឹងម្រាមដៃ ចង្អុលទិសដៅនៃកម្លាំងអេឡិចត្រូម៉ាញេទិច។

)




បើសិនជាខ្សែចម្លងកែងនឹង $\vec{B}(\theta = 90^o)$គេបានម៉ូឌុលកម្លាំងអេឡិចត្រូម៉ាញេទិច

អំពើទៅវិញទៅមករវាងចរន្តត្រង់ពីរ







ខ្សែចម្លងវែងត្រង់ពីរដាក់ស្របគ្នា ឆ្លងកាត់ដោយចរន្តអគ្គិសនីមានទិសដៅដូចគ្នា ខ្សែចម្លងទាំងពីរទាញគ្នាចូលទៅវិញទៅមក។

ខ្សែចម្លងវែងត្រង់ពីរដាក់ស្របគ្នា ឆ្លងកាត់ដោយចរន្តអគ្គិសនីមានទិសដៅផ្ទុយគ្នា ខ្សែចម្លងទាំងពីរច្រានគ្នាចេញ។

ខ្សែចម្លងវែង $l$ ត្រង់ពីរស្របគ្នា ស្ថិតនៅចម្ងាយពីគ្នា $a$ហើយឆ្លងកាត់ដោយចរន្តរៀងគ្នា $I_1$និង$I_2$ នោះកម្លាំងដែលខ្សែចម្លងទាំងពីរមានអំពើលើគ្នាគឺ

$l$ ជាប្រវែងខ្សែចម្លងត្រង់គិតជា$(m)$

$I_1$ , $I_2$ជាអាំងតង់ស៊ីតេចរន្តឆ្លងកាត់ខ្សែចម្លងទី១ និងខ្សែចម្លងទី២ រៀងគ្នាគិតជា(A)

a ចម្ងាយពីខ្សែចម្លងទី១ និងខ្សែចម្លងទី២គិតជា(m)

កម្លាំងអេឡិចត្រូម៉ាញេទិច ៖កាលណាផង់ផ្ទុកបន្ទុកអគ្គិសនី$q$ ផ្លាស់ទីក្នុងដែនម៉ាញេទិច $\vec{B}$ដោយល្បឿន$\vec{v}$នោះផង់រងនូវកម្លាំងអេឡិចត្រូម៉ាញេទិច ៖

មានទំហំ



ផង់ផ្ទុកបន្ទុកអគ្គិសនី$q$ផ្លាស់ទីដោយល្បឿន $\vec{v}$ចូលក្នុងដែនម៉ាញេទិច$\vec{B}$($\vec{v} \perp \vec{B}$)នោះចលនាផង់ជាចលនាវង់ស្មើលើរង្វង់មួយដែលមានកាំ

R ជាកាំរង្វង់ចលនាវង់ស្មើរបស់ផង់ (m) , v ជាល្បឿនរបស់ផង់ (m/s) ,

q ជាបន្ទុករបស់ផង់(c) , B ជាដែនម៉ាញេទិច (T)

**ឧទាហរណ៍១៖** ខ្សែចម្លងត្រង់ប្រវែងអនន្តឆ្លងកាត់ដោយចរន្តI=0.5A ដែលមជ្ឈដ្ឋានជុំវិញជាខ្យល់។

ក. គណនាអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ចំណុច M ចម្ងាយ 2m ពីខ្សែចម្លង។

ខ. គេដឹងថាត្រង់ចំណុច N មានអាំងឌុចស្យុង $10^{-8}T$។ ចូរគណនាចម្ងាយពីចំណុច N ទៅខ្សែចម្លង។

**ចម្លើយ១៖** ក.គណនាអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ចំណុច M ចម្ងាយ2mពីខ្សែចម្លង

តាមរូបមន្ត

$B = \mu_o \frac{I}{2\pi d}$ ដោយ I=0.5A, d=2m , $\mu_o = 4\pi \times 10^{-7}\ (T.m)/A$

$$B = 4\pi \times 10^{-7} \frac{0.5}{2\times\pi\times2} = 5 \times 10^{-8}\ T$$

ខ. គណនាចម្ងាយពីចំណុចNទៅខ្សែចម្លង

តាមរូបមន្ត $B = \mu_o \frac{I}{2\pi d} \Rightarrow d = \frac{2\pi B}{\mu_0 I} (B = 10^{-8}T)$

$$d = \frac{2\times\pi\times10^{-8}}{4\pi\times10^{-7}\times0.5} = 0.1\ m$$

**ឧទាហរណ៍២៖** ខ្សែចម្លងរង្វង់មួយមានផ្ចិត O មានកាំ R=10cm។ រត់កាត់ដោយចរន្តដែលមានអាំងតង់ស៊ីតេ10A។គណនាតម្លៃអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ផ្ចិតOបង្កើតដោយចរន្តក្នុងខ្សែចម្លងដែលមជ្ឈដ្ឋានជុំវិញជាខ្យល់។

**ចម្លើយ២៖** តម្លៃអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ផ្ចិតOបង្កើតដោយចរន្តក្នុងសៀគ្វីរង្វង់

តាមរូបមន្ត $B = \mu_o \frac{I}{2R}$

ដោយ I =10A, R=10cm=0.1m,$\mu_o = 4\pi \times 10^{-7}\ (T.m)/A$

$$B = 4\pi \times 10^{-7} \frac{10}{2\times0.1} = 2\pi \times 10^{-5}\ T = 6.28 \times 10^{-5}\ T$$

**ឧទាហរណ៍៣៖** បូប៊ីនសំប៉ែតមួយមានចំនួនស្ពៀ N=100 ឆ្លងកាត់ដោយចរន្តមានអាំងតង់ស៊ីតេ I=10A ហើយស្ពៀមានកាំមធ្យម R=20cm។ ចូរគណនាតម្លៃអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ផ្ចិត បូប៊ីន។ បើស្នូលបូប៊ីនជាលោហៈមានជម្រាបម៉ាញ៉េទិចធៀប $\mu_r = 1000$។

**ចម្លើយ៣៖** គណនាអាំងឌុចស្យុងម៉ាញ៉េទិចត្រង់ផ្ចិតបូប៊ីន

តាមរូបមន្ត $B = \mu_o \mu_r N \frac{I}{2R}$

ដោយ I=10A, R=20cm=0.2m,$\mu_o = 4\pi \times 10^{-7}\ (T.m)/A, \mu_r = 1000, N = 100$

$$B = 4\pi \times 10^{-7} \times 1000 \times 100 \frac{10}{2\times0.2} = 3.14\ T$$

**ឧទាហរណ៍៨៖** ខ្សែចម្លងមួយមានប្រវែង$l$=25cm ឆ្លងកាត់ដោយចរន្ត I=4A ស្ថិតក្នុងដែនម៉ាញ៉េទិចឯកសណ្ឋានដែលមានអាំងឌុចស្យុង B=2T ។ គណនាកម្លាំងអេឡិចត្រូម៉ាញេទិចដែលមានអំពើលើរបារក្នុងករណីដែលខ្សែចម្លងផ្គុំបានមុំ $\alpha_1 = 30^o, \alpha_2 = 60^o, \alpha_3 = 90^o$ជាមួយខ្សែអាំងឌុចស្យុង។

**ចម្លើយ៨៖** គណនាកម្លាំងអេឡិចត្រូម៉ាញេទិចដែលមានអំពើលើរបារ

តាមរូបមន្ត $F = IlB\ sin\theta$

ដោយ $l$=25cm=0.25m, I=4A, B=2T

ករណី$\alpha_1 = 30^o$ នាំឱ្យ $F_1 = 2 \times 4 \times 0.25\ \ sin30^o = 1\,T$

ករណី$\alpha_2 = 60^o$ នាំឱ្យ $F_2 = 2 \times 4 \times 0.25\ \ sin60^o = 2\frac{\sqrt{3}}{2} = \sqrt{3}\,T$

ករណី$\alpha_3 = 90^o$ នាំឱ្យ $F_2 = 2 \times 4 \times 0.25\ \ sin90^o = 2\,T$

**ឧទាហរណ៍៩៖** គណនាកម្លាំងឡូរិនដែលមានអំពើលើប្រូតុងកំពុងផ្លាស់ទីដោយល្បឿន $v = 4 \times 10^6\,m/s$ ចូលក្នុងដែនម៉ាញេទិចដែលមានទិសដៅកែងនឹងអាំងឌុចស្យុងម៉ាញេទិចB=2T។

**ចម្លើយ៩៖** គណនាកម្លាំងឡូរិនដែលមានអំពើលើប្រូតុង

តាមរូបមន្ត$F_m = |q|vBsin\alpha$

ដោយ $q = 1.6 \times 10^{-19}c, v = 4 \times 10^6\,m/s\,, B = 2T, \alpha = 90°$

$F_m = 1.6 \times 10^{-19} \times 4 \times 10^6 \times 2 \times sin90° = 12.8 \times 10^{-13}N$

## ជំពូក៣ អគ្គិសនីនិងម៉ាញេទិច

### មេរៀនទី២៖ អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

បម្រែបម្រួលដែនម៉ាញេទិចឆ្លងកាត់សៀគ្វីខ្សែចម្លង អាចបង្កើតនូវចរន្តអគ្គិសនី ហៅថា ចរន្តអាំងឌី។ ចរន្តនេះកើតមានតែក្នុងពេលដែលមានបម្រែបម្រួលដែនម៉ាញេទិចប៉ុណ្ណោះ។ តម្លៃនៃអាំងតង់ស៊ីតេចរន្តអាំងឌីអាស្រ័យនឹងល្បឿននៃបម្រែបម្រួលដែនម៉ាញេទិច។
ភ្លុចម៉ាញេទិច គឺជាចំនួនខ្សែដែនម៉ាញេទិចឆ្លងកាត់ផ្ទៃមួយ។ បើអាំងឌុចស្យុងម៉ាញេទិច$\vec{B}$ បង្កើតបានមុំ θ ជាមួយខ្សែកែងនឹងផ្ទៃ នោះភ្លុចម៉ាញេទិចអាចគណនាតាមរូបមន្ត

$$\Phi = BAcos\theta$$

Φ ភ្លុចម៉ាញេទិចត្រូវបានគិតជាវេប៊ែ (Wb)
$B$ ជាម៉ូឌុលនៃវ៉ិចទ័រអាំងឌុចស្យុងម៉ាញេទិច$\vec{B}$ គិតជា (T)
$A$ ជាផ្ទៃ ដែលវ៉ិចទ័រ$\vec{B}$ ឆ្លងកាត់ គិតជា $m^2$
θ ជាមុំផ្គុំឡើងរវាង $\vec{B}$ ជាមួយខ្សែកែងនឹងផ្ទៃ គិតជាដឺក្រេ

កាលណាភ្លុចម៉ាញេទិចឆ្លងកាត់Nស្ពៀ ដែលមានបម្រែបម្រួល ΔΦក្នុងរយៈពេល$\Delta t$ កម្លាំងអគ្គិសនីចលករអាំងឌីដែលកើតមាន

$$E = -N\frac{\Delta\Phi}{\Delta t} = -N\frac{\Phi_f - \Phi_i}{t_f - t_i}$$

$E$ ជាកម្លាំងអគ្គីសនីចលករអាំងឌី គិតជាវ៉ុល ($V$)
$N$ ជាចំនួនស្ពៀរបស់របុំខ្សែចម្លង
$\Phi_f$ ជាភ្លុចម៉ាញេទិចស្រេច គិតជា(Wb)
$\Phi_i$ ជាភ្លុចម៉ាញេទិចដើម គិតជា(Wb)
$t_f$ ជារយៈពេលស្រេច គិតជាវិនាទី($s$)
$t_i$ ជារយៈពេលដើម គិតជាវិនាទី($s$)

ក្នុងករណីដែលគេយកចិត្តទុកដាក់តែតម្លៃកម្លាំងអគ្គិសនីចលករអាំងឌី ច្បាប់ផារ៉ាដេអាចសរសេរដូចខាងក្រោម

$$|E| = N\frac{|\Delta\Phi|}{\Delta t} = N\frac{|\Phi_f - \Phi_i|}{t_f - t_i}$$

ច្បាប់ឡិនសម្តែងថា ចរន្តអាំងឌ្វីមានទិសដៅយ៉ាងណាឱ្យផលរបស់វាប្រឆាំងនឹងបុព្វហេតុ ដែលបង្កើតវា ឬចរន្តអាំងឌ្វីបង្កើតនូវដែនម៉ាញេទិចមួយថ្មី ដើម្បីប្រឆាំងនឹងបម្រែបម្រួលភ្លុចម៉ាញេទិចដែលឆ្លងកាត់វា។

បើរបារខ្សែចម្លងមានប្រវែង $l$ ផ្លាស់ទីដោយល្បឿន $v$ កែងនឹងដែនម៉ាញេទិចដែលមានអាំងឌុចស្យុង $B$ កម្លាំងអគ្គិសនីចលករអាំងឌ្វីដែលកើតក្នុងខ្សែចម្លងគឺ

$$\boxed{|E| = Bvl}$$

$|E|$ ជាកម្លាំងអគ្គិសនីចលករអាំងឌ្វី គិតជាវ៉ុល $(V)$

$v$ ជាល្បឿនរបារពេលផ្លាស់ទីកែងនឹងដែនម៉ាញេទិច គិតជា$(m/s)$

$l$ ជាប្រវែងរបារខ្សែចម្លងគិតជា$(m)$

ជនិតា និងម៉ូទ័រ គឺជាឧបករណ៍សម្រាប់បំលែងរវាងថាមពលមេកានិច និងថាមពលអគ្គីសនី។ ជនិតាអគ្គីសនីប្រើថាមពលមេកានិចដើម្បីផលិតនូវថាមពលអគ្គីសនី។កន្សោមកម្លាំងអគ្គីសនីចលករ

$$\boxed{e(t) = NBA\omega\ \sin\omega t = E_m \sin\omega t}$$

ដែល $\boxed{E_m = NBA\omega}$ ជាកម្លាំងអគ្គីសនីចលករអតិបរិមាគិតជាវ៉ុល $(V)$

$N$ ជាចំនួនស្ពៀនៃបូប៊ីន, $B$អាំងឌុចស្យុងម៉ាញេទិច $(T)$,

$A$ ផ្ទៃរបស់បូប៊ីន $m^2$, $\omega$ ល្បឿនមុំនៃបូប៊ីន$(\frac{rad}{s})$

**ឧទាហរណ៍១៖** ទម្រខ្សែចម្លងពីរដាក់ឱ្យស្របគ្នាក្នុងប្លង់ដេកដែលចុងទាំងពីររបស់វាភ្ជាប់គ្នាដោយរេស៊ីស្តង់$R = 2\Omega$ទម្រទាំងពីរនៅឃ្លាតគ្នាចម្ងាយ20cm។របារលោហៈ MN មួយដាក់ឱ្យកែងលើទម្រទាំងពីរ។ប្លង់ទម្រកែងនឹងដែនម៉ាញ៉េទិចឯកសណ្ឋានមានអាំងឌុចស្យុង B=0.02T។ គេរុញរបារ MN ឱ្យផ្លាស់ទីលើទម្រទាំងពីរដោយល្បឿន50 $m/s$។ គណនាអាំងតង់ស៊ីតេចរន្តអាំងឌ្វីឆ្លងកាត់រេស៊ីស្តង់ បើរបារនិងទម្រមានរេស៊ីស្តង់អាចចោលបាន។

**ចម្លើយ១៖** គណនាអាំងតង់ស៊ីតេចរន្តអាំងឌ្វីឆ្លងកាត់រេស៊ីស្តង់

គេមាន $I = \frac{|E|}{R}$

កម្លាំងអគ្គិសនីចលករអាំងឌ្វី$|E| = Bvl$

ដោយ B=0.02T, $v = 50\, m/s$ ,$l$ =20cm=0.2cm, $R = 2\Omega$

$$|E| = 0.02 \times 50 \times 0.2 = 0.2V$$

នាំឱ្យ $I = \frac{0.2}{2} = 0.1A$



facebook.com/moeys.gov.kh www.moeys.gov.kh google.com/+moeys

**ឧទាហរណ៍២៖** ស៊ុមមួយមានរាងចតុកោណកែងមានចំនួនស្ពៀN=30ស៊ុមនេះស្ថិតនៅក្នុងដែនម៉ាញេទិចឯកសណ្ឋានចន្លោះប៉ូលមេដែករាងUដែលអាំងឌុចស្យុងB=0.2Tដោយប្លង់ស៊ុមកែងនឹងខ្សែអាំងឌុចស្យុង។ដោយដឹងថាវិមាត្រa=20cm, b=10cmគេទាញស៊ុមឱ្យផ្លាស់ទីស្របខ្លួនវាយ៉ាងរហ័សចេញពីចន្លោះប៉ូលមេដែកដោយប្រើរយៈពេលតែ$\Delta t = 0.01s$។

ក. គណនាកម្លាំងអគ្គិសនីចលករអាំងឌីដែលកកើតក្នុងស៊ុម។

ខ. បើស៊ុមជាសៀគ្វីបិទមានរេស៊ីស្តង់R=10Ωគណនាចរន្តអាំងឌី។

**ចម្លើយ២៖** ក. គណនាកម្លាំងអគ្គិសនីចលករអាំងឌីដែលកកើតក្នុងស៊ុម

គេមាន$|E| = N\frac{|\Delta\Phi|}{\Delta t} = N\frac{A|B_f - B_i|}{\Delta t}$

ដោយN=30, $A = a \times b = 0.2m \times 0.1m = 0.02m^2$

$B_f = 0, B_i = 0.2T, \quad \Delta t = 0.01s$

នាំឱ្យ$|E| = 30\frac{0.02|0-0.2|}{0.01} = 12V$

ខ. គណនាចរន្តអាំងឌី

គេមាន $I = \frac{|E|}{R} = \frac{12}{10} = 1.2A$ (រេស៊ីស្តង់R=10Ω)

**ឧទាហរណ៍៣៖** ខ្សែចម្លងមួយប្រវែង$1.6m$ត្រូវបានរុំជាបូប៊ីនមួយមានកាំ$3.2cm$។ បើបូប៊ីនវិលដោយល្បឿន 95 ជុំក្នុងមួយនាទី ក្នុងដែនម៉ាញេទិចដែលមានតម្លៃ $0.07T$ ចូរគណនាតម្លៃអតិបរិមានៃកម្លាំងអគ្គិសនីចលករអាំងឌី។

**ចម្លើយ៣៖** គណនាតម្លៃអតិបរិមានៃកម្លាំងអគ្គិសនីចលករអាំងឌី

គេមាន $E_m = NBA\omega$

ដោយ $l = 1.6m, \quad R = 3.2cm = 32 \times 10^{-3}m, B = 0.07T, \ f = \frac{95}{60}Hz = 1.58Hz$

$A = \pi R^2 = 3.14 \times (32 \times 10^{-3})^2 = 3.21 \times 10^{-3}m^2$

តែ $N = \frac{l}{2\pi R} = \frac{1.6}{2\times 3.14 \times 32 \times 10^{-3}} = 8$ ស្ពៀនិង $\omega = 2\pi f = 2 \times 3.14 \times 1.58 = 10rad/s$

$E_m = 8 \times 0.07 \times 3.21 \times 10^{-3} \times 10 = 0.018V$

## ជំពូក៣ អគ្គិសនីនិងម៉ាញេទិច

## មេរៀនទី៣៖ អូតូអាំងឌុចស្យុង

បាតុភូតអូតូអាំងឌុចស្យុងកើតមានកាលណាមានបម្រែបម្រួលចរន្តនៅក្នុងសៀគ្វី។ ចរន្តអូតូអាំងឌុីកើតក្នុងបូប៊ីនប្រឆាំងទប់នឹង ការកកើតនៃចរន្តនៅក្នុងសៀគ្វី។ ផលរបស់វាកើតមានកាលណាអាំងតង់ស៊ីតេចរន្តប្រែប្រួល។ឧទាហរណ៍៖ បាតុភូតអូតូអាំងឌុចស្យុងកើតមាននៅពេលគេបិទសៀគ្វីធ្វើឱ្យអំពូលដែលជាស៊េរីជាមួយ និងបូប៊ីនមិនភ្លឺតាមរបប ធម្មតាភ្លាមទេ។

អាំងឌុចតង់ ជាមេគុណសមមាត្ររវាង Φនិង *i*អាស្រ័យនឹងលក្ខណៈធរណីមាត្រនៃសៀគ្វី

$$\Phi = L\,i$$

Φ ជាភ្លុចម៉ាញេទិចគិតជាវេប៊ែ (Wb)

$L$ ជាអាំងឌុចតង់ គិតជា ហង់រី $(H)$

$i$ ជាចរន្តអគ្គិសនី គិតជា អំពែ $(A)$

កម្លាំងអគ្គិសនីចលករអូតូអាំងឌុី ដែលកើតមានក្នុងបូប៊ីនឱ្យដោយកន្សោម

$$e = -L\frac{di(t)}{dt}$$

$e$ ជាកម្លាំងអគ្គីសនីចលករអូតូអាំងឌុីគិតជាវ៉ុល $(V)$

$L$ ជាអាំងឌុចតង់ គិតជា ហង់រី $(H)$

$i(t)$ ជាកន្សោមចរន្តអគ្គិសនី

អាំងឌុចតង់នៃសូលេណូអ៊ីតដែលគ្មានស្នូលដែកឱ្យដោយរូបមន្ត

$$L = \mu_o\frac{N^2}{l}A$$

$L$ អាំងឌុចតង់គិតជា$(H)$ ; Φជាភ្លុចម៉ាញេទិចគិតជាវេប៊ែ (Wb)

$i$ ជាចរន្តអគ្គិសនី គិតជា អំពែ $(A)$ , $A$ ផ្ទៃមុខកាត់សូលេណូអ៊ីតគិតជា$(m^2)$ ,

$l$ ប្រវែងសូលេណូអ៊ីតគិតជា$(m)$ ; $N$ជាចំនួនស្ពៀសូលេណូអ៊ីត

$R$ កាំសូលេណូអ៊ីតគិតជា$(m)$ ; $D$ អង្កត់ផ្ចិតសូលេណូអ៊ីតគិតជា$(m)$

តង់ស្យុង $V_{AB}$ រវាងគោលនៃបូប៊ីន $(r, L)$ ឱ្យដោយ $V_{AB} = ri + L\frac{di}{dt}$

$r$ ជារេស៊ីស្តង់ក្នុងរបស់បូប៊ីន គិតជា$(\Omega)$

$i$ ជាកន្សោមចរន្តអគ្គិសនី

$L$ អាំងឌុចតង់គិតជា$(H)$

$V_{AB}$ ជាតង់ស្យុង រវាងគោលនៃបូប៊ីនគិតជាវ៉ុល $(V)$

ថេរពេល$\tau$ក្នុងសៀគ្វី $(R,L)$ ឱ្យដោយរូបមន្ត $\boxed{\tau = \frac{L}{R}}$

$\tau$ ជាថេរពេលក្នុងសៀគ្វី $(R,L)$ គិតជាវិនាទី$(s)$

$R$ ជារេស៊ីស្តង់សរុបរបស់សៀគ្វី $(R,L)$គិតជា$(\Omega)$

សមីការចរន្តអគ្គិសនីនៅខណៈ $t$ក្នុងសៀគ្វី$(R,L)$

$$\boxed{i(t) = I_p\left(1 - e^{-\frac{t}{\tau}}\right)}$$

ដែល $I_p = \frac{E}{R}$ជាអាំងតង់ស៊ីតេចរន្តក្នុងរបបអចិន្ត្រៃយ៍គិតជាអំពែ $(A)$

$\tau$ ជាថេរពេលក្នុងសៀគ្វី $(R,L)$ គិតជាវិនាទី$(s)$

$t$ ជាខណៈពេលជាមួយគិតជាវិនាទី$(s)$

$i(t)$ ជាកន្សោមចរន្តអគ្គិសនី

ថាមពលអេឡិចត្រូម៉ាញេទិច $E_L$ ក្នុងបូប៊ីនមួយដែលមានអាំងឌុចតង់ $L$ ឆ្លងកាត់ដោយចរន្តដែលមានអាំងតង់ស៊ីតេចរន្ត $i$ ស្មើ

$$\boxed{E_L = \frac{1}{2}Li^2}$$

$E_L$ ជាថាមពលអេឡិចត្រូម៉ាញេទិចក្នុងបូប៊ីនគិតជាស៊្វូល $(J)$

$i$ ជាតម្លៃចរន្តអគ្គិសនី គិតជាអំពែ $(A)$

$L$ អាំងឌុចតង់របស់បូប៊ីនគិតជា$(H)$

ក្នុងរយៈពេលនៃលំយោលអគ្គិសនីសេរីមិនថយនៃសៀគ្វី $(L,C)$តង់ស្យុងរវាងគោលនៃកុងដង់សាទ័រគោរពតាមសមីការឌីផេរ៉ង់ស្យែល៖

$$\boxed{\frac{dV_c(t)}{dt} + \frac{1}{LC}V_c(t) = 0}$$

$L$ ជាអាំងឌុចតង់របស់បូប៊ីនគិតជា$(H)$

$C$ ជាកាប៉ាស៊ីតេ របស់កុងដង់សាទ័រ គិតជា $(F)$

$V_c(t)$ ជាកន្សោមតង់ស្យុងរបស់គោលកុងដង់សាទ័រ

អនុគមន៍ $\boxed{V_c(t) = V_m\cos\left(\frac{2\pi}{T_o} + \phi_0\right)}$ ជាចម្លើយរបស់សមីការឌីផេរ៉ង់ស្យែល$\frac{dV_c}{dt} + \frac{1}{LC}V_c = 0$

$T_o$ ជាខួបផ្ទាល់របស់លំយោលអគ្គិសនីដែល $\boxed{T_o = 2\pi\sqrt{LC}}$ គិតជា$(s)$

$V_m$ តម្លៃតង់ស្យុងអតិបរិមា គិតជា$(V)$

$\phi_0$ ជាផាសដើមរបស់លំយោលអគ្គិសនីគិតជា$(rad)$

ប្រេកង់ផ្ទាល់របស់លំយោលអគ្គិសនីគឺ $f_o = \frac{1}{2\pi\sqrt{LC}}$ គិតជា $(Hz)$។

ពុលសាស្យុងផ្ទាល់របស់លំយោលអគ្គិសនីគឺ $\omega_o = \sqrt{1/LC}$ គិតជា $(rad/s)$។

កន្សោមបន្ទុកនៃកុងដង់សាទ័រ $q(t) = q_m \cos(\frac{2\pi}{T_o} + \phi_0)$

ដែល $q_m$ ជាបន្ទុកអតិបរិមារបស់កុងដង់សាទ័រគិតជាកូឡុំ $(c)$

កន្សោមអាំងតង់ស៊ីតេចរន្ត $i(t) = i_m \cos(\frac{2\pi}{T_o} + \phi_0 + \frac{\pi}{2})$

ដែល $i_m$ ជាតម្លៃអាំងតង់ស៊ីតេចរន្តអតិបរិមាក្នុងសៀគ្វី $(L, C)$ គិតជាអំពែ $(A)$

ទំនាក់ទំនងរវាង អាំងតង់ស៊ីតេចរន្តអតិបរិមា $i_m$ និងបន្ទុកអតិបរិមារបស់កុងដង់សាទ័រ $q_m$ គឺ

$$i_m = q_m \frac{2\pi}{T_o} = CV_m \frac{2\pi}{T_o}$$

ក្នុងករណីសៀគ្វីអ៊ីដេអាល់ $(LC)$ ថាមពលនៃសៀគ្វីរក្សាតម្លៃថេរ

$$E_{LC} = E_L + E_C = \frac{1}{2}CV_c^2 + \frac{1}{2}Li^2 = \text{ថេរ}$$

$E_{LC}$ ថាមពលសរុបនៃសៀគ្វី $(LC)$ គិតជាស៊ូល $(J)$

$E_L$ ថាមពលម៉ាញេទិច ក្នុងបូប៊ីន គិតជាស៊ូល $(J)$

$E_C$ ថាមពលអគ្គិសនី ក្នុងកុងដង់សាទ័រ គិតជាស៊ូល $(J)$

តែកាលណាបើ $V_C = V_L$ , $i = 0$ ឬ កាលណាបើ $V_C = 0$, $i = i_m$ នោះគេអាចសរសេរ

$$E_{LC} = \frac{1}{2}CV^2 = \frac{1}{2}Li_m^2$$

**ឧទាហរណ៍១៖** សូលេណូអ៊ីតមួយមានប្រវែង ℓ = 1m មានអង្កត់ផ្ចិត D = 4cm និងមានចំនួនស្ពៀ N = 100 ។ យក $\mu_o = 4\pi \times 10^{-7} T{\cdot}m/A$

①. គណនាអាំងឌុចតង់នៃសូលេណូអ៊ីត ?

②. គេធ្វើឱ្យចរន្តប្រែប្រួល i = 5t + 2 ឆ្លងកាត់សូលេណូអ៊ីត។

គណនាកម្លាំងអគ្គិសនីចលករអូតូអាំងឌី ដែលកើតមានក្នុងសូលេណូអ៊ីត ?

**ចម្លើយ១៖** ①. គណនាអាំងឌុចតង់នៃសូលេណូអ៊ីត

តាមរូបមន្ត $L = \mu_o \frac{N^2}{l} A$

ដោយ $\mu_o = 4\pi \times 10^{-7} \frac{T.m}{A}, N = 100, A = \pi\frac{D^2}{4} = \pi\frac{0.04^2}{4} = 1.256 \times 10^{-3} m^2$

$l = 1m$

$L = 4 \times 3.14 \times 10^{-7} \frac{100^2 \times 1.256 \times 10^{-3}}{1} = 1.57 \times 10^{-5} H$

②. គណនាកម្លាំងអគ្គិសនីចលករអូតូអាំងឌី

គេធ្វើឱ្យចរន្តប្រែប្រួល $i = 5t + 2$ ឆ្លងកាត់សូលេណូអ៊ីត

តាមរូបមន្ត $e = -L\frac{di(t)}{dt}$

ដោយ $L = 0.181mH = 1.81 \times 10^{-4}H, \frac{di(t)}{dt} = \frac{d(5t+2)}{dt} = 5A/s$

$$e = -(1.57 \times 10^{-5}) \times 5 = -7.8 \times 10^{-5}V$$

**ឧទាហរណ៍២៖** ក.គណនាអាំងឌុចតង់របស់សូលេណូអ៊ីតដែលមានចំនួនស្ពៀ300 ។ប្រសិនបើប្រវែងសូលេណូអ៊ីត 25cm និងផ្ទៃមុខកាត់របស់សូលេណូអ៊ីត $4cm^2$។

ខ. គណនាកម្លាំងអគ្គិសនីចលករអូតូអាំងឌីក្នុងសូលេណូអ៊ីត បើចរន្តថយចុះដោយអត្រា $50\ A/s$។

**ចម្លើយ២៖** ក.អាំងឌុចតង់របស់សូលេណូអ៊ីត

តាមរូបមន្ត $L = \mu_o\frac{N^2}{l}A$

ដោយ $\mu_o = 4\pi \times 10^{-7}\ (T.m)/A, N = 300, A = 4cm^2 = 4 \times 10^{-4}m^2$ ,

$l = 25cm = 0.25m$

$$L = 4\pi \times 10^{-7}\frac{300^2}{0.25}4 \times 10^{-4} = 0.181mH$$

ខ.គណនាកម្លាំងអគ្គិសនីចលករអូតូអាំងឌីក្នុងសូលេណូអ៊ីត

តាមរូបមន្ត $e = -L\frac{di(t)}{dt}$

ដោយ $L = 0.181mH = 1.81 \times 10^{-4}H, \frac{di(t)}{dt} = -50A/s$

នាំឱ្យ $e = -(1.81 \times 10^{-4}) \times (-50) = 9.05mV$

**ឧទាហរណ៍៣៖** ក. គេផ្ទុកកុងដង់សាទ័រ មួយដែលមានកាប៉ាស៊ីតេ $C = 1\mu F$ក្រោមតង់ស្យុង $V = E = 2V$ គណនាថាមពលដែលស្តុកក្នុងកុងដង់សាទ័រនៅពេលផ្ទុក។

ខ. កុងដង់សាទ័រដែលផ្ទុករួចនោះ ត្រូវបានគេតភ្ជាប់ទៅនឹងគោលនៃបូប៊ីនមួយដែលមានអាំងឌុចតង់ $L = 0.1H$ និងមានរេស៊ីស្តង់ក្នុងអាចចោលបាន។គណនាអាំងតង់ស៊ីតេចរន្តអតិបរិមា$i_m$៕

**ចម្លើយ៣៖** ក.គណនាថាមពលដែលស្តុកក្នុងកុងដង់សាទ័រនៅពេលផ្ទុក

តាមរូបមន្ត $E_C = \frac{1}{2}CV_c^2$ ដោយ $C = 1\mu F = 10^{-6}F$និង $V = E = 2V$

$$E_C = \frac{1}{2}10^{-6} \times 2^2 = 2 \times 10^{-6}J$$

ខ.គណនាអាំងតង់ស៊ីតេចរន្តអតិបរិមា

តាមច្បាប់រក្សាថាមពល $E_C = E_L = \frac{1}{2}Li_m^2$

នាំឱ្យ$i_m = \sqrt{\frac{2E_C}{L}} = \sqrt{\frac{2\times2\times10^{-6}}{0.1}} = 6.32 \times 10^{-3}A$

**ឧទាហរណ៍៨៖** បូប៊ីនមួយមានរេស៊ីស្តង់ក្នុង $R = r = 6\Omega$ និងមានអាំងឌុចតង់ $L$។ គណនាអាំងឌុចតង់ បើថេរពេលមានតម្លៃ $\tau = 2 \times 10^{-3}s$។

**ចម្លើយ៨៖**គណនាអាំងឌុចតង់

តាមរូបមន្ត $\tau = \frac{L}{R} \Rightarrow L = \tau \times R$

ដោយ $R = r = 6\Omega$និង $\tau = 2 \times 10^{-3}s$

នាំឱ្យ $L = 0.003 \times 6 = 0.018H$

**ឧទាហរណ៍៩៖** គណនាអាំងឌុចតង់ របស់សៀគ្វីលំយោលអគ្គិសនី $LC$ ដែលមានប្រេកង់ $f = 120Hz$ នៅពេលកុងដង់សាទ័រ $C = 8\mu F = 8 \times 10^{-6}F$។

**ចម្លើយ៩៖**គណនាអាំងឌុចតង់

តាមរូបមន្ត $f = \frac{1}{2\pi\sqrt{LC}} \Rightarrow L = \frac{1}{f^2 4\pi^2 C}$

ដោយ$f = 120Hz$និង $C = 8\mu F = 8 \times 10^{-6}F$

នាំឱ្យ$L = \frac{1}{120^2 \times 4 \times 3.14^2 \times 8 \times 10^{-6}} = 0.22H = 220mH$

## ជំពូក៣ អគ្គិសនីនិងម៉ាញេទិច

### មេរៀនទី៤៖ សៀគ្វីចរន្តឆ្លាស់

ចរន្តឆ្លាស់ ជាចរន្តអគ្គិសនីដែលប្តូរទិសដៅពីរដងក្នុងមួយខួប។
ចរន្តឆ្លាស់ដែលងាយជាងគេ គឺចរន្តឆ្លាស់ស៊ីនុយសូអ៊ីតដែលមានអាំងតង់ស៊ីតេខណៈ $i(t)$ នៅខណៈ $t$ មានកន្សោម $i(t) = I_m \sin(\omega t + \phi)$

$i(t)$ជាកន្សោមចរន្ត ; $\omega$ជាពុលសាស្យុង គិតជា $\left(\frac{rad}{s}\right)$,
$I_m$ជាអំព្លីទុតឬអាំងតង់ស៊ីតេចរន្តអតិបរិមា គិតជា$(A)$
$\phi$ ជាផាសដើមរបស់ចរន្តឆ្លាស់ស៊ីនុយសូអ៊ីត$(rad)$

ចរន្តឆ្លាស់មានផលបី គឺ ផលគីមី ផលកម្តៅ និងផលម៉ាញេទិច។
អាំងតង់ស៊ីតេប្រសិទ្ធនៃចរន្តឆ្លាស់ជាអាំងតង់ស៊ីតេចរន្តជាប់ដែលឆ្លងកាត់រេស៊ីស្តង់ដូចគ្នាហើយក្នុងរយៈពេលដូចគ្នាមានភាយបរិមាណកម្តៅស្មើគ្នា។ គេបាន

$$I = \frac{I_m}{\sqrt{2}}$$

$I$ ជាអាំងតង់ស៊ីតេប្រសិទ្ធគិតជា$(A)$ ,
$I_m$ជាអាំងតង់ស៊ីតេអតិបរិមាគិតជា$(A)$

កន្សោមតង់ស្យុងខណៈ មានកន្សោម $V(t) = V_m \sin(\omega t)$

$V(t)$ជាកន្សោមតង់ស្យុង
$V_m$ជាតង់ស្យុងអតិបរិមាគិតជា$(V)$

តង់ស្យុងប្រសិទ្ធ ស្មើនឹងតង់ស្យុងថេរមួយរវាងចុងទាំងពីរនៃរេស៊ីស្តង់សុទ្ធមួយដែលក្នុងរយៈពេលដូចគ្នាញ៉ាំងឱ្យមានបរិមាណកម្តៅស្មើគ្នា។គេបាន

$$V = \frac{V_m}{\sqrt{2}}$$

$V$ជាតង់ស្យុងប្រសិទ្ធគិតជា$(V)$

កំណាត់សៀគ្វីមានតែបូប៊ីនសុទ្ធ មានអាំប៉េដង់ $Z = Z_L = L\omega$ ហើយអាំងតង់ស៊ីតេចរន្តយឺតផាស $\frac{\pi}{2}$ជាងតង់ស្យុង ។

$Z_L$ជាអាំប៉េដង់បូប៊ីនសុទ្ធ គិតជា$(\Omega)$
$L$ជាអាំងឌុចតង់របស់បូប៊ីនគិតជា$(H)$

កំណាត់សៀគ្វីមានតែរេស៊ីស្តង់សុទ្ធ មានអាំប៉េដង់ $\boxed{Z = Z_R = R}$ ហើយអាំងតង់ស៊ីតេចរន្ត និងតង់ស្យុងស្របផាសគ្នា។

$Z_R$ ជាអាំប៉េដង់រេស៊ីស្តង់សុទ្ធ គិតជា$(\Omega)$

$R$ ជារេស៊ីស្តង់របស់រេស៊ីស្ទរ គិតជា$(\Omega)$

កំណាត់សៀគ្វីមានតែកុងដង់សាទ័រសុទ្ធ មានអាំប៉េដង់ $\boxed{Z = Z_C = \frac{1}{C\omega}}$ ហើយ អាំងតង់ស៊ីតេចរន្ត លឿនផាស $\frac{\pi}{2}$ ជាងតង់ស្យុង ។

$Z_R$ជាអាំប៉េដង់កុងដង់សាទ័រសុទ្ធ គិតជា$(\Omega)$

$C$ជាកាប៉ាស៊ីតេរបស់កុងដង់សាទ័រ គិតជា$(F)$

កំណាត់សៀគ្វី$(RC)$មានរេស៊ីស្តង់ និង កុងដង់សាទ័រ តជាស៊េរី មានអាំប៉េដង់ $\boxed{Z = \sqrt{R^2 + \left(\frac{1}{C\omega}\right)^2}}$ ហើយអាំងតង់ស៊ីតេចរន្តលឿនផាសជាងតង់ស្យុង $\phi$ដែល

$$\boxed{tan\phi = \frac{\frac{1}{C\omega}}{R}}$$

កំណាត់សៀគ្វី$(RL)$មានបូប៊ីន និងរេស៊ីស្តង់ តជាស៊េរី មានអាំប៉េដង់ $\boxed{Z = \sqrt{R^2 + (L\omega)^2}}$ ហើយអាំងតង់ស៊ីតេចរន្ត យឺតផាសជាងតង់ស្យុង $\phi$ដែល

$$\boxed{tan\phi = \frac{L\omega}{R}}$$

កំណាត់សៀគ្វី$(RLC)$មានបូប៊ីន$(L)$ កុងដង់សាទ័$(C)$ និងរេស៊ីស្តង់$(R)$តជាស៊េរីមានអាំប៉េដង់

$$\boxed{Z = \sqrt{R^2 + (L\omega - \frac{1}{C\omega})^2}}$$

គម្លាតផាសរវាង អាំងតង់ស៊ីតេចរន្ត និងតង់ស្យុងអាចគណនាតាមរូបមន្ត

$$\boxed{tan\phi = \frac{\left(L\omega - \frac{1}{C\omega}\right)}{R} \text{ ឬ } cos\phi = \frac{R}{Z}}$$

បើ $L\omega > \frac{1}{C\omega}$ចរន្តយឺតផាសជាងតង់ស្យុង។

បើ $L\omega < \frac{1}{C\omega}$ចរន្តលឿនផាសជាងតង់ស្យុង។

បើ $L\omega = \frac{1}{C\omega}$ចរន្តស្របផាសជាមួយតង់ស្យុង។

ក្នុងសៀគ្វី $RLC$ រេសូណង់អគ្គិសនីកើតមានកាលណា៖

$$L\omega = \frac{1}{C\omega} \text{ ឬ } LC\omega^2 = 1$$

ដូចនេះ $Z = R\ ,\phi = 0$ អាំងតង់ស៊ីតេចរន្តមានតម្លៃអតិបរិមាហើយ $i(t)$ និង $V(t)$ ស្របផាសគ្នា។

អានុភាពមធ្យមផ្ទេរក្នុងសៀគ្វីមួយជាផលធៀបរវាងថាមពលសរុបកនឹងរយៈពេលផ្ទេរនោះ៖។

$$P = \frac{W}{t} \text{ នាំឱ្យ } P = VIcos\varphi$$

$cos\varphi$ ជាកត្តាអានុភាព

$P$ ជាអានុភាពមធ្យម $(W)$

$W$ ជាថាមពលសរុប $(J)$

$VI$ ជាអានុភាពទំនង $(W)$

ត្រង់ស្វូម៉ាទ័រជាប្រដាប់សម្រាប់ដំឡើង ឬបន្ថយតង់ស្យុងចរន្តឆ្លាស់។

រូបមន្តផលធៀបបំលែងត្រង់ស្វូម៉ាទ័រ

$$\frac{V_2}{V_1} = \frac{n_2}{n_1} = K$$

$V_2$ ជាតង់ស្យុងប្រសិទ្ធនៅរបុំមធ្យម គិតជាវ៉ុល $(V)$

$V_1$ ជាតង់ស្យុងប្រសិទ្ធនៅរបុំបឋម គិតជាវ៉ុល $(V)$

$n_2$ ជាចំនួនស្ពៀនៅរបុំមធ្យម

$n_1$ ជាចំនួនស្ពៀនៅរបុំបឋម

$K$ ជាផលធៀបបម្លែងរបស់ត្រង់ស្វូម៉ាទ័រ

បើ $K > 1$ ត្រង់ស្វូម៉ាទ័រនោះជាប្រដាប់ដំឡើងតង់ស្យុងហៅថា ស្វូករ៉ុលទ័រ។

បើ $K < 1$ ត្រង់ស្វូម៉ាទ័រនោះជាប្រដាប់បន្ថយតង់ស្យុងហៅថា ស៊្វរ៉ុលទ័រ។

បើ $K = 1$ ត្រង់ស្វូម៉ាទ័រនោះជាត្រង់ស្វូម៉ាទ័រអ៊ីដេអាល់(សុទ្ធ )។

ទិន្នផលត្រង់ស្វូម៉ាទ័រ ឱ្យដោយរូបមន្ត

$$Rd = \frac{Pe_2}{Pe_1}$$

$Pe_2$ ជាអានុភាពច្រកចេញនៃត្រង់ស្វូ (នៅរបុំមធ្យម) គិតជាវ៉ាត់ $(W)$

$Pe_1$ ជាអានុភាពច្រកចូលនៃត្រង់ស្វូ (នៅរបុំបឋម) គិតជាវ៉ាត់ $(W)$

**ឧទាហរណ៍១៖** តង់ស្យុងច្រកចេញរបស់ប្រភពចរន្តឆ្លាស់ ឱ្យដោយ$V(t) = (200V)sin\omega t$។ គណនាចរន្តប្រសិទ្ធ ពេលភ្ជាប់ទៅនឹង រេស៊ីស្តង់$R = 100\Omega$។

**ចម្លើយ១៖** គណនាចរន្តប្រសិទ្ធ

តាមរូបមន្ត $I = \frac{V}{R}$តែ $V = \frac{V_m}{\sqrt{2}}$

ដោយ $V_m = 200V$នាំឱ្យ $V = \frac{200}{\sqrt{2}} = 141V$

នោះ $I = \frac{V}{R} = \frac{141}{100} = 1.41A$

**ឧទាហរណ៍២៖** សៀគ្វី $AC$ បូប៊ីនសុទ្ធ ដែលមានអាំងឌុចតង់$L = 25mH$និងតង់ស្យុងប្រសិទ្ធ $V = 150V$ ។ គណនាអាំប៉េដង់នៃសៀគ្វី $AC$ និងចរន្តប្រសិទ្ធ ប្រសិនបើប្រេកង់សៀគ្វី$f = 60Hz$។

**ចម្លើយ២៖** គណនាអាំប៉េដង់នៃសៀគ្វី $AC$

កំណាត់សៀគ្វីមានតែបូប៊ីនសុទ្ធ មានអាំប៉េដង់ $Z = Z_L = L\omega = 2\pi fL$

ដោយ $L = 25mH$ និង $f = 60Hz$

$Z_L = 2\pi(600)(25 \times 10^{-3}) = 9.42\Omega$

ចរន្តប្រសិទ្ធ$I = \frac{V}{Z_L} = \frac{150}{9.42} = 15.9A$

**ឧទាហរណ៍៣៖** កុងដង់សាទ័រ មានកាប៉ាស៊ីតេ $8\mu F$ត្រូវបានភ្ជាប់ ទៅនឹងប្រភពចរន្តឆ្លាស់ ដែលមានប្រេកង់ $f = 60Hz$ និងតង់ស្យុងប្រសិទ្ធ$V = 150V$។គណនាអាំប៉េដង់និង ចរន្តប្រសិទ្ធរបស់សៀគ្វី។

**ចម្លើយ៣៖** គណនាអាំប៉េដង់និង ចរន្តប្រសិទ្ធនៃសៀគ្វី

កំណាត់សៀគ្វីមានតែកុងដង់សាទ័រ សុទ្ធ មានអាំប៉េដង់$Z = Z_C = \frac{1}{C\omega}$

ដោយ $C = 8 \times 10^{-6}F$ និង $f = 60Hz \Rightarrow \omega = \frac{1}{2\pi f} = \frac{1}{2\pi \times 60} = 377rad/s$

$Z_C = \frac{1}{C\omega} = \frac{1}{8\times10^{-6}\times377} = 332\Omega$

អាំងតង់ស៊ីតេប្រសិទ្ធ$I = \frac{V}{Z_C} = \frac{150}{332} = 0.452A$

**ឧទាហរណ៍៤៖** សៀគ្វី ចរន្តឆ្លាស់ $RLC$តជាស៊េរី មាន $R = 425\Omega,\ L = 1.25H,\ C = 3.5\mu F,\ \omega = 377rad/s$ និង $V_m = 150V$។

ក. កំណត់ $Z_L,\ Z_C,\ Z$

ខ. គណនាចរន្តអតិបរិមារបស់សៀគ្វី

គ. គណនាគម្លាតផាស រវាងចរន្ត និងតង់ស្យុង

ឃ. គណនាតង់ស្យុងអតិបរិមានិង កន្សោមតង់ស្យុង រវាងគោលនៃធាតុនីមួយៗ

**ចម្លើយ៤៖** ក. កំណត់ $Z_L,\ Z_C,\ Z$

តាម $Z_L = L\omega,\ Z_C = \frac{1}{C\omega},\quad Z = \sqrt{R^2 + (L\omega - \frac{1}{C\omega})^2}$

ដោយ $R = 425\Omega,\ L = 1.25H,\ C = 3.5\mu F,\ \omega = 377rad/s$

$Z_L = L\omega = (1.25)(377) = 471\Omega$

$Z_C = \frac{1}{C\omega} = \frac{1}{(3.5\times10^{-6})(377)} = 758\Omega$

$Z = \sqrt{425^2 + (471 - 758)^2} = 513\Omega$

ខ. គណនាចរន្តអតិបរិមារបស់សៀគ្វី

$$I = \frac{V}{Z} = \frac{150}{513} = 0.292A$$

គ. គណនាគម្លាតផាស រវាងចរន្ត និងតង់ស្យុង

$$tan\phi = \frac{\left(L\omega - \frac{1}{C\omega}\right)}{R} \Rightarrow \phi = tan^{-1}\left(\frac{\left(L\omega - \frac{1}{C\omega}\right)}{R}\right) = tan^{-1}\left(\frac{(471-758)}{425}\right) = -34°$$

ឃ. គណនាតង់ស្យុងអតិបរិមារវាងគោលនៃធាតុនីមួយៗ

$$V_m(R) = I_m R = (0.292)(425) = 124V$$

$$V_m(L) = I_m Z_L = (0.292)(471) = 138V$$

$$V_m(C) = I_m Z_C = (0.292)(758) = 221V$$

កន្សោមតង់ស្យុង រវាងគោលនៃធាតុនីមួយៗ

$$V_R(t) = V_m(R)\sin(\omega t) = 124\sin(377t)$$

$$V_L(t) = V_m(L)\sin\left(\omega t + \frac{\pi}{2}\right) = V_m(L)\cos(\omega t) = 138\cos(377t)$$

$$V_c(t) = V_m(C)\sin\left(\omega t - \frac{\pi}{2}\right) = -V_m(L)\cos(\omega t) = -221\cos(377t)$$